# ក្រុមប្រឹក្សារាជធានី ខេត្ត ស្រុក ខណ្ឌ ត្រូវមានគណនេយ្យភាពចំពោះ ប្រជាពលរដ្ឋ និងរាជរដ្ឋាភិបាល

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅក្រោមជាតិ- គ.ជ.អ.ប បានរៀបចំកិច្ចប្រជុំផ្សព្វផ្សាយស្ដីអំពី **“កិច្ចដំណើរការនៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិតាមច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ”**ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្ដេចអគ្គមហាសេនា~បតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា កាលពីថ្ងៃទី២៨ ខែមករា ឆ្នាំ២០០៩ សាលមហោស្រពចតុមុខ។ នាឱកាសនេះដែរ មានតំណាងសមាជិករដ្ឋាភិបាល គ្រប់ក្រសួង មន្ទីរ រដ្ឋសភា ព្រឹទ្ធសភា តំណាងរដ្ឋទូត រាជទូតនៅក្នុងប្រទេស អជ្ញាធរនៅថ្នាក់ក្រោមជាតិ រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ សង្គមស៊ីវិលទាំងអន្តរជាតិនិងក្នុងស្រុកចំនួន៦៣៤រូបបានចូលរួម។

ក្រោយពីការបង្ហាញអំពីវឌ្ឍនភាពនៃដំណើរការណ៍ការអនុវត្ត គោលការណ៍វិមជ្ឈការ និងវិសហមជ្ឈការដោយឯកឧត្ដម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ-គ.ជ.អ.ប រួចមក **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** បានមានប្រសាសន៍ដឹកនាំដ៏ខ្ពង់ខ្ពស់ដែលមានអត្ថន័យទាំងស្រុងដូចតទៅ :



សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**
ក្នុងឱកាសផ្ដល់ប្រសាសន៍ ដឹកនាំដ៏ខ្ពង់ខ្ពស់ក្នុងពិធីផ្សព្វផ្សាយ

“ថ្ងៃនេះខ្ញុំមានសេចក្ដីរីករាយដោយបានមកចូលរួមក្នុងពិធីជួបជុំដ៏មានសារៈសំខាន់នេះនិងមានឱកាសបានពិភាក្សាជាមួយគ្នាអំពីវឌ្ឍនភាព និងផែនការស្ដីពីកិច្ចដំណើរការវិមជ្ឈការ និងវិសហមជ្ឈការ។ ខ្ញុំសូម សម្ដែងនូវការស្វាគមយ៉ាងកក់ក្ដៅ និងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះការយកចិត្តទុកដាក់និងការ ចូលរួមរបស់ឯកឧត្ដម លោកជំទាវ លោក លោកស្រីនៅក្នុងវិស័យកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការដ៏មានសារៈសំខាន់នេះ។

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមថ្លែងអំណរគុណចំពោះឯកឧត្ដម **ស ខេង** ដែលបានធ្វើរបាយការណ៍ស្ដីពីវឌ្ឍនភាព និងផែនការសម្រាប់ការអនុវត្តកិច្ចដំណើរការវិមជ្ឈការ និងវិសហមជ្ឈការ និងសូមវាយតម្លៃខ្ពស់ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ឯកឧត្ដម ក្នុងការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ចាប់តាំងពី ដំណាក់កាលនៃការបង្កើតគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ ហៅកាត់ថា គ.ឃ.ស រហូតដល់គណៈកម្មា ធិការជាតិដឹកនាំការងារកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ ហៅកាត់ថា គ.ជ.វ.វ និងគណៈកម្មាធិការ ជាតិសម្រាប់ការអភិវឌ្ឍបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ហៅកាត់ថា

គ.ជ.អ.ប នាពេលនេះ។ ខ្ញុំក៏ សូមសំដែងនូវការកោតសរសើរចំពោះការរួមចំណែកយ៉ាងសកម្មរបស់ឯកឧត្តម លោកជំទាវ ជាសមាជិក សមាជិកានៃគណៈកម្មាធិការនានាខាងលើផងដែរ។

យើងទាំងអស់គ្នាបានដឹងហើយថា គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ហៅកាត់ថា "**គ.ជ.អ.ប**" ត្រូវបានបង្កើតឡើងដោយផ្អែកលើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលជាច្បាប់រៀបចំអង្គការមួយ។ ខ្ញុំចាត់ទុកថា នេះជាឱកាសដំបូងបំផុតដែលយើងមានលទ្ធភាពជួបជជែក ពិភាក្សាគ្នាយ៉ាងទូលំទូលាយអំពីវិមជ្ឈការនិងវិសហមជ្ឈការ បន្ទាប់ពីការបង្កើត **គ.ជ.អ.ប** ដែលខ្ញុំសូមសំដែងនូវការស្វាគមជាថ្មីម្តងទៀត ចំពោះឱកាសដ៏មានសារៈសំខាន់នេះ។ មុននេះបន្តិច យើងបានស្តាប់អំពីសមិទ្ធិផលដែលបានកសាងឡើង ក្នុងការអនុវត្តច្បាប់រៀបចំអង្គការ និងអំពីផែនការរយៈពេលខ្លី មធ្យម និងរយៈពេលវែង សម្រាប់អនាគតខាងមុខ។ ផែនការទាំងនេះ បានយកចិត្តទុកដាក់ទៅលើលិខិត បទដ្ឋានច្បាប់ និងភាពចាំបាច់ដទៃទៀត សម្រាប់គម្រោងការរៀបចំបោះឆ្នោតជ្រើសរើស ក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ នាខែឧសភាឆ្នាំនេះ និងភាពចាំបាច់នានាសម្រាប់ដំណាក់កាលបន្ទាប់ពីការបោះឆ្នោតភ្លាម ព្រមទាំងភាពចាំបាច់នានាក្នុងការអនុវត្តកិច្ចដំណើរការវិមជ្ឈការនិងវិសហមជ្ឈការ សម្រាប់រយៈពេលមធ្យម និងរយៈពេលវែង។

## ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី!

ទោះបីជាមានសភាពការណ៍ដ៏លំបាក ពោលគឺវិបត្តិកលយុគហិរញ្ញវត្ថុដ៏ខ្លាំងក្លានៅលើពិភពលោក ក៏ដោយក៏រាជរដ្ឋាភិបាលអាចរក្សាបានជារួមនូវស្ថេរភាពម៉ាក្រូសេដ្ឋកិច្ចដែលអាចធានាបាននូវកំណើនសេដ្ឋកិច្ចក្នុងអត្រាប្រមាណ៧% ស្របតាមការរំពឹងចង់បាន។ នៅឆ្នាំ ២០០៨ ថ្វីត្បិតថា អតិផរណាបានកើនឡើងតាំងពីដើមឆ្នាំរហូតដល់ពាក់កណ្តាលឆ្នាំ ជាចំបងគឺដោយសារសម្ពាធពីខាងក្រៅ ក្នុងនោះមានការឡើងថ្លៃប្រេងឥន្ធនៈ និងថ្លៃស្បៀង និងថ្លៃទំនិញប្រើប្រាស់ផ្សេងៗនៅលើទីផ្សារអន្តរជាតិ គួបផ្សំនឹងកត្តាផ្ទៃក្នុងមួយចំនួន ក៏ប៉ុន្តែអត្រានៃអតិផរណានេះបានធ្លាក់ចុះមកវិញចាប់ពីពាក់កណ្តាលឆ្នាំមក ដោយសារតែការដាក់ចេញនូវវិធានការគ្រប់គ្រងជាកញ្ចប់ តាមវិធានការការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ទាំងវិធានការគោលនយោបាយរូបិយវត្ថុ និងធនាគារ យ៉ាងហ្មត់ចត់និងយ៉ាងទាន់ពេលវេលារបស់រាជរដ្ឋាភិបាល។ ដោយឡែក វិស័យធនាគារនិងហិរញ្ញវត្ថុ ជាពិសេសប្រតិបត្តិការរបស់បណ្តាធនគារនៅក្នុងប្រទេសនាពេលបច្ចុប្បន្ន ក៏កំពុងមានសកម្មភាពដំណើរការជាធម្មតា ដោយពុំមានទទួលរងផលប៉ះពាល់ធំដុំ ពីវិបត្តិកលយុគហិរញ្ញវត្ថុសាកលនោះទេ។

ពិនិត្យជារួម កំណើនសេដ្ឋកិច្ចនៅក្នុងទសវត្សចុងក្រោយនេះមានសន្ទុះល្អ គិតជាមធ្យមក្នុងអត្រា ៩.៤% ក្នុងរយៈពេល៥ឆ្នាំ ពីឆ្នាំ ២០០៣-២០០៧ កំណើនមានអត្រាមធ្យម ១០.៦% ក្នុងនោះឆ្នាំ ២០០៥ កំណើនខ្ពស់ជាងគេ គឺ១៣.៣% កំណើនក្នុងឆ្នាំ២០០៦មានអត្រា ១០.៨% និង១០.២ សម្រាប់ឆ្នាំ ២០០៧។ អតិផរណាដែលមានអត្រា១៩.៧% ក្នុងឆ្នាំ២០០៨ បានបន្តធ្លាក់ចុះរហូតដល់ចុងឆ្នាំ២០០៩។ អត្រានេះនឹងអាច

ចុះមកនៅត្រឹមតួលេខតែមួយខ្ទង់ ក្នុងរង្វង់ ៧%។ អត្រាប្តូរប្រាក់មានស្ថេរភាពល្អ ជាទូទៅមធ្យម ៤,០៧២ រៀល ក្នុងមួយដុល្លារ។ ម្យ៉ាងទៀត ដោយសារការអនុវត្តនយោបាយរូបិយវត្ថុប្រុងប្រយត្ន័ ដោយការខិតខំរបស់រាជរដ្ឋាភិបាល ទុនបម្រុងអន្តរជាតិបានកើនឡើងដល់ជាង២ពាន់លានដុល្លារ ដែលអាចធានាបានប្រមាណជាង៣ខែនៃការនាំចូលទំនិញ និងសេវាសម្រាប់ការប្រើប្រាស់ក្នុងស្រុក។ ជាការពិត វិបត្តិព្យុះគលយុគហិរញ្ញវត្ថុដែលកំពុងតែបោកបក់លើសាកលលោកនាពេលបច្ចុប្បន្ននេះ នឹងបន្តផ្តល់បច្ច័យអាក្រក់ដល់សេដ្ឋកិច្ចកម្ពុជាក្នុងរយៈពេលមធ្យម២ឬ៣ឆ្នាំខាងមុខទៀត។ ទោះបីយ៉ាងណាក៏ដោយ ដោយមានគោលនយោបាយ និងយុទ្ធសាស្ត្រត្រឹមត្រូវ គួបផ្សំជាមួយនឹងការដឹកនាំគ្រប់គ្រងរស់រវើក និងហ្មត់ចត់ជាប្រចាំ ដែលធានាបាននូវស្ថេរភាពនយោបាយ វឌ្ឍនភាពក្នុងកិច្ចខិតខំប្រឹងប្រែងកែទម្រង់ គំនិតផ្តួចផ្តើមដ៏សកម្មនៃវិស័យឯកជន ការបន្តនូវ កិច្ចគាំទ្រពីដៃគូអភិវឌ្ឍន៍វការ ព្រមទាំងលំហូរនៃការវិនិយោគផ្ទាល់ពីបរទេស រាជរដ្ឋាភិបាលនៅតែរំពឹងទុកថា សេដ្ឋកិច្ចកម្ពុជានឹងនៅតែបន្តស្ថិតនៅក្នុងភាពរឹងមាំ ហើយគោលដៅនិងយុទ្ធសាស្ត្រចតុកោណកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន ឱ្យបានយ៉ាងហោច១%ក្នុងមួយឆ្នាំ នៅតែអាចសម្រេចបានតាមការរំពឹងទុក។ ជាងនេះទៅទៀត អ្វីដែលជាប្រការសំខាន់បំផុតដ៏គួឱ្យកត់សម្គាល់នោះ គឺបញ្ហាប្រឈមខាងផ្នែកសេដ្ឋកិច្ចក្នុងឆ្នាំកន្លងទៅនេះ មិនអាចបង្វែរឬរុញច្រានកម្ពុជាឱ្យឃ្លាតឆ្ងាយពីគន្លងលទ្ធិប្រជាធិបតេយ្យ សេរី ពហុបក្ស ដ៏រឹងមាំនោះទេ។ ក្នុងសភាពការណ៍ដ៏លំបាកនេះ រាជរដ្ឋាភិបាលមានសេចក្តីក្លាហានដ៏ពេញលេញ និងឆន្ទៈដ៏មោះមុត រៀបចំដំណើរការបានប្រកបដោយជោគជ័យនូវការបោះឆ្នោតមួយ ដែលសាធារណមតិជាតិនិងអន្តរជាតិ ទទួលស្គាល់ថា ត្រឹមត្រូវ សេរី និងយុត្តិធម ស្របតាមគោលការណ៍លទ្ធិប្រជាធិបតេយ្យ។ តាមរយៈលទ្ធផលនៃការបោះឆ្នោតនេះ រាជរដ្ឋាភិបាលបានចូលកាន់តំណែងរបស់ខ្លួន ដោយបានដាក់ចេញនិងប្តេជ្ញាជំរុញអនុវត្តន៍ឱ្យបានជោគជ័យ ក្នុងស្មារតីទទួលខុសត្រូវខ្ពស់បំផុតនូវយុទ្ធសាស្ត្រចតុកោណ ដើម្បីកំណើនការងារ សមធម៌ និងប្រសិទ្ធភាពនៅកម្ពុជា ដំណាក់កាលទី២ ក្នុងនោះ រាជរដ្ឋាភិបាលបានប្តេជ្ញាអនុវត្តវិធានការមុតស្រួចនានាដើម្បីសម្រេចឱ្យបាននូវគោលដៅជាអាទិភាពបួនយ៉ាងគឺ ទី១- ការធានាឱ្យបាននូវចីរភាព និងសន្តិភាព ស្ថេរភាពនយោបាយ សន្តិសុខ និងសណ្តាប់ធ្នាប់សង្គម សំដៅលើកស្ទួយនីតិរដ្ឋ ការពារសិទ្ធិនិងសេចក្តីថ្លៃថ្នូររបស់មនុស្ស និងលទ្ធិប្រជាធិបតេយ្យសេរី ពហុបក្ស។ ទី២- ការធានាឱ្យបាននូវកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាពក្នុងអត្រាប្រមាណ៧%ក្នុងមួយឆ្នាំ នៅលើមូលដ្ឋានទូលាយជាងមុន និងមានសមត្ថភាពប្រកួតប្រជែងជាងមុន ក្នុងបរិការអត្រាអតិផរណាទាប ក្នុងកម្រិតតួលេខមួយខ្ទង់។ ទី៣-ការធានាសម្រេចឱ្យបាននូវការកាត់បន្ថយអត្រានៃភាពក្រីក្រឱ្យបានលើស១%ក្នុងមួយឆ្នាំ និងការធានាកែលំអសូចនាករសំខាន់ៗក្នុងវិស័យសង្គមកិច្ច ជាពិសេសក្នុងវិស័យអប់រំ សុខាភិបាល និងសមភាពយេនឌ័រ។ ទី៤- ការធានាបង្កើនវិសាលភាព ប្រសិទ្ធភាព និងគុណភាពនៃសេវាសាធារណៈឱ្យកាន់តែប្រសើរឡើង ដោយទទួលបាននូវការជឿទុកចិត្ត។ ពិតណាស់ថា គោលដៅជាអាទិភាពទាំងបួនយ៉ាងខាងលើនេះ គឺជាគោលដៅប្រកបដោយមហិច្ឆតាខ្ពស់ណាស់ ជាពិសេសក្នុងបរិការបច្ចុប្បន្នដែលសេដ្ឋកិច្ចនិងប្រពន្ធ័ហិរញ្ញវត្ថុពិភពលោក កំពុងតែជួបប្រឈម

នូវវិបត្តិកលយុគយ៉ាងជ្រាលជ្រៅ។ រាជរដ្ឋាភិបាលយល់ច្បាស់ថា បញ្ហាប្រឈមនានា និងជាពិសេស ភារកិច្ចនៃការលុបបំបាត់ភាពក្រីក្រ មិនអាចសម្រេចបានក្នុងរយៈពេលតែមួយថ្ងៃឬមួយឆ្នាំនោះឡើយ។ ក៏ប៉ុន្តែ ផ្អែកលើបទពិសោធន៍ដែលយើងមាន ផ្អែកលើសមិទ្ធផលដែលយើងសម្រេចបាន និងផ្អែកលើឆន្ទៈនិងការប្តេជ្ញាចិត្តឥតរាថយ ព្រមទាំងស្មារតីសាមគ្គីដ៏ទូលំទូលាយរបស់ជាតិកម្ពុជាទាំងមូល ក្នុងការជំរុញនូវសកម្មភាពប្រទាក់ក្រឡាគ្នា ប្រកបដោយចីរភាព ជាប់មិនដាច់ក្នុងគ្រប់ការដ្ឋានទាំងអស់ រាជរដ្ឋាភិបាលជឿជាក់ថា យើងពិតជាអាចរួមគ្នាឈានទៅសម្រេចបាននូវចក្ខុវិស័យនៃការកសាងសង្គមកម្ពុជាមួយ ដែលមានសន្តិភាព ស្ថេរភាពនយោបាយ សន្តិសុខ និងសណ្តាប់ធ្នាប់សង្គម មានការអភិវឌ្ឍប្រកបដោយចីរភាព និងសមធម៌ ជាមួយនឹងការគោរពយ៉ាងខ្ជាប់ខ្ជួននូវគោលការណ៍ប្រជាធិបតេយ្យសេរី ពហុបក្ស ការគោរពសិទ្ធិនិងសេចក្តីថ្លៃថ្នូររបស់មនុស្ស។




ពាក់ព័ន្ធទៅនឹងកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ខ្ញុំសូមបញ្ជាក់ថា រាជរដ្ឋាភិបាលបានដាក់ចេញនូវចក្ខុវិស័យជាយុទ្ធសាស្ត្ររបស់ខ្លួនស្តីពីវិមជ្ឈការ និងវិសហមជ្ឈការ នៅក្នុងក្របខណ្ឌយុទ្ធសាស្ត្រស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ដែលបានអនុម័តឆ្នាំ២០០៥។ បច្ចុប្បន្ននេះ យើងបានអនុម័តច្បាប់រៀបចំអង្គការ កំណត់កាលបរិច្ឆេទនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សានានា ហើយនិងបានបង្កើត គ.ជ.អ.ប។ ទាំងអស់នេះគឺជាគ្រឹះដ៏សំខាន់សម្រាប់កិច្ចដំណើរការ ដែលការងារជាក់ស្តែងបានចាប់ផ្តើមពីឥឡូវនេះទៅហើយ។ យើងបានជ្រើសរើសយកមាគ៌ានេះ ក្នុងគោលបំណងធានាឱ្យបាននូវកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព នៅលើមូលដ្ឋានទូលាយជាងមុន និងមានសមត្ថភាពប្រកួតប្រជែងជាងមុន ព្រមទាំងការ

ពង្រឹងការគ្រប់គ្រងនិងការផ្ដល់នូវសេវាសាធារណៈប្រកបដោយគុណភាព ដើម្បីឆ្លើយតបតម្រូវការនានារបស់មូលដ្ឋាន និងការកាត់បន្ថយភាពក្រីក្រ។ ជាការពិតយើងទទួលស្គាល់ថា រាជរដ្ឋាភិបាលពិតជាមិនអាចមានលទ្ធភាពផ្ដល់នូវតម្រូវការដ៏ទូលំទូលាយនៃសេវាកម្មសាធារណៈនៅទូទាំងប្រទេស ចាប់តាំងពីរាជធានីភ្នំពេញ រហូតដល់តំបន់ជនបទឆ្ងាយដាច់ស្រយាលប្រកបដោយប្រសិទ្ធិភាពនោះទេ។ ដូច្នេះ ជាមួយនឹងការអនុម័តនូវគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ យើងបានសម្រេចឱ្យមានការផ្លាស់ប្ដូរជាសារវ័ន្តនូវរបៀបរបបធ្វើការងាររបស់យើង។ បច្ចុប្បន្ននេះ យើងកំពុងរៀបចំបង្កើតនូវប្រព័ន្ធរដ្ឋបាលថ្នាក់ក្រោមជាតិមួយ ជាមួយ នឹងការប្រគល់មុខងារនានា ដែលរួមមានមុខងារផ្ដល់សេវានានា រួមជាមួយធនធានហិរញ្ញវត្ថុ ធនធាន មនុស្ស និងធនធានដទៃៗទៀតពីថ្នាក់ជាតិទៅឱ្យទៅថ្នាក់ក្រោមជាតិ។

យើងទទួលស្គាល់ថា ដើម្បីសម្រេចបានកិច្ចការនេះ ចាំបាច់យើងត្រូវមានពេលវេលាសមស្របសម្រាប់អនុវត្តគោលនយោបាយវិមជ្ឈការនិងវិសហមជ្ឈការ និងច្បាប់រៀបចំអង្គការ។ ដូច្នេះហើយ បច្ចុប្បន្ននេះយើងកំពុងតាក់តែងនូវផែនការអនុវត្តជាតិដ៏សំខាន់មួយដែលមានឈ្មោះថា **"កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ"**។ កម្មវិធីជាតិនេះនឹងត្រូវចាប់ផ្ដើមអនុវត្តចាប់ពីដើមឆ្នាំ២០១០តទៅ ដែលនឹងដាក់ចេញនូវយុទ្ធសាស្ត្រ និងកម្មវិធីអនុវត្តរយៈពេល១០ឆ្នាំ សម្រាប់គ្របដណ្ដប់ទាំងការអនុវត្តចំពោះមុខនៃច្បាប់រៀបចំអង្គការ និងទាំងយុទ្ធសាស្ត្ររយៈពេលវែង ដែលចាំបាច់ក្នុងការសម្រេចនូវចក្ខុវិស័យដែលបានចែងនៅក្នុងក្របខ័ណ្ឌយុទ្ធសាស្ត្រស្ដីពីវិមជ្ឈការ និងវិសហមជ្ឈការ។ ដូច្នេះ កម្មវិធីជាតិនេះអាចរំពឹងថា ជាកញ្ចប់នៃភាពផ្សារភ្ជាប់តែមួយដែលរួមមានខ្លឹមសារ និងកិច្ចដំណើរការចាំបាច់នានាសម្រាប់:

- ទីមួយ អនុវត្តក្របខណ្ឌ័យុទ្ធសាស្ត្រស្ដីពីវិមជ្ឈការនិងវិសហមជ្ឈការ ក្នុងរយៈពេលយូរអង្វែង ដែលអាចកែសម្រួលបានតាមការចាំបាច់។

- ទីពីរ អនុវត្តច្បាប់រៀបចំអង្គការ។

- ទីបី កំណត់នូវគោលនយោបាយ និងយុទ្ធសាស្ត្រចាំបាច់ផ្សេងៗទៀតដែលពាក់ព័ន្ធនឹងវិមជ្ឈការ និង វិសហមជ្ឈការ។

- ទីបួន កំណត់ និងអនុវត្តគម្រោងនានា សម្រាប់គាំទ្រការកសាងសមត្ថភាព ការវិនិយោគ ការផ្ដល់សេវា ការគ្រប់គ្រងដីធ្លី ការគ្រប់គ្រងធនធានធម្មជាតិនិងបរិស្ថាន ព្រមទាំងការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន របស់ថ្នាក់ក្រោមជាតិ

- ទីប្រាំ កំណត់និងអនុវត្តនូវក្របខ័ណ្ឌអនុវត្តមួយដែលមានលក្ខណៈលំអិតនិងបែងចែកជាដំណាក់កាល ដែលរួមមានកម្មវិធីសកម្មភាពរៀបចំបុគ្គលិកនិងធនធាននានា

ព្រមទាំងជំនួយបច្ចេកទេសដែល មានកាលបរិច្ឆេទច្បាស់លាស់។

**ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី!**

ជោគជ័យនៃការអនុវត្តកម្មវិធីនេះ គឺអាស្រ័យជាសំខាន់ទៅលើអ្វីដែលយើងត្រូវបំពេញឱ្យបានក្នុង រយៈពេលប៉ុន្មានខែនិងប៉ុន្មានឆ្នាំខាងមុខនេះ។ ឆ្លៀតឱកាសនេះ ខ្ញុំសូមគូសបញ្ជាក់នូវបញ្ហាគន្លឹះមួយចំនួនដែលយើងត្រូវប្រកាន់ យកនាពេលខាងមុខនេះ។

**គ.ជ.អ.ប** មានការទទួលខុសត្រូវជាទូទៅ នៅក្នុងការធានាដល់ការអនុវត្តច្បាប់រៀបចំអង្គការ ហើយនិងត្រូវបានប្រគល់នូវភារកិច្ចដ៏ច្បាស់លាស់ក្នុងការពិនិត្យមើលឡើងវិញនូវ ***" ការទទួលខុសត្រូវ និងមុខងារនានា របស់ក្រសួង ស្ថាប័ន មន្ទីរជំនាញ ការិយាល័យជំនាញ និងអាជ្ញាធរមូលដ្ឋានគ្រប់ថ្នាក់ ដើម្បីកំណត់នូវមុខងារដែល ត្រូវផ្ទេរទៅឱ្យក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ "*** ។ កិច្ចការនេះជាគន្លឹះ គឺជាស្នូលនៃការអនុវត្តកំណែទម្រង់នេះ។

ចំណុចនេះក៏សូមបញ្ជាក់ជូនបណ្តាស្ថាប័នឱ្យហើយ។ ការអនុវត្តតាមបែបដែលយើងបានធ្វើកន្លងមកនេះ គឺជាការអនុវត្តតាមបែបគេហៅថាការប្រមូលផ្តុំអំណាច ដែលក្នុងនោះគឺប្រព័ន្ធខ្សែទទឹងនិងខ្សែបណ្តោយតែងតែបង្កើតឡើងនូវបញ្ហាជាប់មិនដាច់ក្នុងរយៈពេល៣០ឆ្នាំដែលយើងបានគ្រប់គ្រងប្រទេសរហូតមកដល់ពេលនេះ។ ពិតមែនតែផ្នែកខ្លះៗយើងបានដោះស្រាយក៏ប៉ុន្តែជាទូទៅនៅមានបញ្ហារខេករខាកនៅឡើយទេ។ ច្បាប់រៀបចំអង្គការដែលយើងនឹងត្រូវរៀបចំនៅពេលខាងមុខនេះត្រូវតែពិនិត្យមើលមិនមែនដូចកាលកន្លងទៅដែលយើងនាំគ្នាប្រើពាក្យមិនទាន់ត្រូវ។ គ្រាន់តែគេហៅថាផ្តល់សិទ្ធិអំណាចតាមបែបមួយដែលអនុញ្ញាតឱ្យក្រសួងណាមួយចូលរួមនៅក្នុងការផ្ទេរអំណាចសម្រេចវិនិយោគក្នុងគម្រោង២លានដុល្លារនោះហើយមន្ទីរនីមួយៗឱ្យសិទ្ធិទៅ។ដូច្នោះនោះមិនមែនជាការផ្ទេរមុខនាទីទេមិនមែនវិសហមជ្ឈការទេមិនមែនជាការផ្ទេរអំណាចទេ។ វាគ្រាន់តែជាការផ្តល់សិទ្ធិទៅចុះហត្ថលេខាហើយទីចុងបញ្ចប់មកសុំរដ្ឋមន្ត្រីតែដដែលហ្នឹង។ ដល់ពេលខាងមុខនេះយើងនឹងបង្កើតនូវរដ្ឋបាលថ្នាក់ក្រោមជាតិដែលមានគណនេយ្យភាពជាមួយនឹងគណៈអភិបាលហើយក្រុមប្រឹក្សាមានគណនេយ្យភាពជាមួយនឹងរាជរដ្ឋាភិបាល។

ដូច្នេះបញ្ហានេះទាមទារឱ្យមានការផ្លាស់ប្តូរឥរិយាបថជាបឋមពីស្ថាប័នដែលធ្លាប់តែគ្រប់គ្រងចង្អុលរហូតទៅដល់ថ្នាក់ការិយាល័យស្រុកនោះ។ត្រូវមានការផ្លាស់ប្តូរបើគ្មានការផ្លាស់ប្តូរពីរដ្ឋមន្ត្រីពីប្រធានស្ថាប័ននៅទីក្រុងភ្នំពេញនោះទេច្បាប់អង្គការនេះក៏មិនអាចទៅរួចដែរ។ ខ្ញុំសូមបញ្ជាក់ថាជាភព្វ័សំណាងហើយដែលប្រទេសខ្មែរតូចនោះយើងមើលឆាប់ឃើញ។ ប៉ុន្តែបើដូចប្រទេសចិនវិញបើអនុវត្តន៍តាមរបៀបខ្មែរយើងប្រទេសចិនមិនអាចគ្រប់គ្រងប្រទេសបានទេ។ ប្រទេសចិនមានប្រព័ន្ធមួយដែលអំណាចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិរបស់ចិនមានទំហំ ធំធេងណាស់។ ដូចកាលកន្លងទៅ ខ្ញុំគ្រាន់តែលើកប៉ុណ្ណេះគឺវាឈឺក្បាលណាស់ទៅហើយ។ ឧទាហរណ៍ ប្រធានមន្ទីរ មួយលោករដ្ឋមន្ត្រីគាត់ចង់តែងតាំងឈ្មោះក ឯចៅហ្វាយខេត្តចង់តែងតាំងឈ្មោះ ខ

។ ដូច្នេះបញ្ហានេះជាបញ្ហាគន្លឹះ នៅក្នុងបញ្ហាទាក់ទងនិងកំណត់មុខងារដែលត្រូវផ្ទេរទៅឱ្យក្រុមប្រឹក្សា។ បានសេចក្តីថាមិនមែនកំណត់សិទ្ធិមួយផ្នែកណាមួយឱ្យទៅទេ។ អញ្ចឹងបានជាចំណុចនេះវាមានភាពប្រទាក់ក្រឡាគ្នាខ្លាំងណាស់។ ហើយបើសិនជាយើងស្លាយអំណាចនៅខេត្តថាអំណាចរបស់ចៅហ្វាយខេត្តធំដល់ឡើងមកធ្វើរដ្ឋមន្ត្រីថាអំណាចរដ្ឋមន្ត្រីធំ។ ដណ្តើមគ្នារបៀបហ្នឹង ស្លាយមិនរួចទេ។ យើងធ្វើនេះធ្វើសម្រាប់ជាតិ សម្រាប់ ទុកឱ្យជាតិទាំងមូលទៅពេលក្រោយ។ ឥឡូវនេះ ដោយសារ រដ្ឋបាលថ្នាក់ក្រោមជាតិមិនមានសិទ្ធិ មិនមានធនធានក្នុងដៃគ្រប់គ្រាន់ហ្នឹងហើយ បានជាសូម្បីផ្លូវជង្ហុកបន្តិចបន្តួច គ្មានអ្នកណាជួសជុល ហើយថា អាហ្នឹង ជារបស់ក្រសួងសាធារណការ។ ផ្លូវជង្ហុកបន្តិចបន្តួចហ្នឹង រហូតមានពេលខ្លះខ្ញុំចង់ថា វៃនឹងគល់ឫស្សីហៅវៃនឹងគល់ឫស្សី។ ថ្ងៃមុនខ្ញុំធ្វើដំណើរតាមផ្លូវ ឃើញផ្លូវខូចហើយអភិបាលក្រុង កែប ជុតិមា ថាអាហ្នឹងដីខេត្តកណ្តាលទេ។អញ្ចឹងខេត្តកណ្តាលជួសជុលសិនទៅ។ ប៉ុន្មានអាទិត្យមុននេះខ្ញុំធ្វើដំណើរម្តងទៀតទៅឃើញមួយកន្លែងទៀតស្ថិតនៅតែប៉ុន្មានរយម៉ែត្រពីកន្លែងខូចលើកមុន។បញ្ហាហ្នឹងថ្ងៃក្រោយទៅអត់មានបន្ទោសរដ្ឋមន្ត្រីទេ។ កុងត្រូលជជុះវាកើតឡើងវិញដោយសារចៅហ្វាយខេត្តមិនមើល។ បន្តិចទៀត មានក្រុមប្រឹក្សានៅថ្នាក់ខេត្ត និងមានគណៈអភិបាលខេត្ត។ ដូច្នេះឥរិយាបថក្នុងការគ្រប់គ្រងត្រូវផ្លាស់ប្តូរហើយត្រូវចាប់ផ្តើមដំបូងនៅស្ថាប័នថ្នាក់ជាតិនេះ។ ប៉ុន្តែយ៉ាងណាក៏ដោយទោះចង់ឬមិនចង់ច្បាប់អង្គការបានចេញរួចហើយ ។យើងត្រូវនិយាយគ្នាឱ្យច្បាស់ចំពោះបញ្ហានេះ។ ខ្ញុំបានប្រាប់រឿងហ្នឹងតាំងពីធ្វើសិក្ខាសាលានៅក្រុងព្រះសីហនុឆ្នាំ២០០៥ម្ល៉េះ។

 

ខ្ញុំបានលើកឡើងឱ្យត្រៀមលក្ខណៈសម្បត្តិឱ្យ ហើយទៅ។ បើអ្វីក៏ស្ថិតនៅលើ យើងនៅខាងលើយើងលូកម៉េចនឹងដល់?។ សេវាសាធារណៈផ្សេងៗ ត្រូវឱ្យអង្គភាពថ្នាក់ក្រោមជាតិ រដ្ឋបាលថ្នាក់ក្រោមជាតិ មានការទទួលខុសត្រូវច្បាស់លាស់អំពីបញ្ហានេះ។ ព្រោះយើងចាត់ចែងមិនគ្រប់ទេ។ ចំណូលចំណាយអីក៏អញ្ចឹងដែរ។ បើចំណូលខាងលើយកមកអស់ហើយ ចាំបាច់រកធ្វើអី? ធ្វើដូចមិនដឹងៗអញ្ចឹងទៅ។

បើរកលុយបានមកប្រមូលមកភ្នំពេញអស់រលីងដដែលហ្នឹងអញ្ចឹងមិនបាច់ខំរកទេ ។ប៉ុន្តែនិយាយអញ្ចឹងមិនមែនបាន សេចក្តីថាឱ្យលោកយកទាំងអស់ហើយរាជរដ្ឋាភិបាលអត់មានអីចិញ្ចឹមទាហាន ប៉ូលីស កិច្ចការបរទេសនិងចំណាយ ផ្សេងៗនោះទេ។ ឧទាហរណ៍ច្រកគយនៅតាមខេត្តព្រះសីហនុនិងនៅតាមព្រលានយន្តហោះ។

ព្រោះការពិតទៅ រាជរដ្ឋាភិបាលអត់មានដីនៅទេ។ និយាយឱ្យច្បាស់ រាជរដ្ឋាភិបាល អត់មានដីនៅទេណា។ រាជរដ្ឋាភិបាល មានទីតាំងនៅក្នុងភូមិ។ រាល់ថ្ងៃយើងត្រូវចុះបញ្ជីចុះអីគោរពក្រុម គោរពខណ្ឌ គោរពសង្កាត់ គោរពភូមិ។ កុំថាទេអញរដ្ឋមន្ត្រីអញចាំបាច់គោរពស្អី។ អញ្ចឹងចំណុចនេះខ្ញុំគ្រាន់តែចង់បញ្ជាក់ថាត្រូវត្រៀមខ្លួនឱ្យហើយ ។បើទោះបីថាចង់ឬមិនចង់ក៏ត្រូវតែអនុវត្តន៏នូវច្បាប់អង្គការដែលយើងបានចេញរួចមកហើយដើម្បីជំរុញដំណើរការវិមជ្ឈការនិងវិសហមជ្ឈការនេះ។ អំណាចខ្លះត្រូវប្រគល់ឱ្យដាច់ទៅតែម្តងហើយរដ្ឋាភិបាលត្រូវកុងត្រូលមើលពីលើ។

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិត្រូវពិនិត្យមើលអំពីបញ្ហាហ្នឹងដើម្បីនឹងដំណើរការអ្វីខ្លះ? ត្រូវបែងចែកផ្ទេរគ្នាយ៉ាងម៉េចខ្លះ? ឧទាហរណ៍ និយាយអំពីបញ្ហាថវិកា ច្បាប់ថវិកាគឺជាច្បាប់អធិបតេយ្យហើយអត់មានអ្នកណារំលោភបានទេ។ ប៉ុន្តែក្នុងការអនុវត្តច្បាប់ថវិកានេះ ថវិកាណាត្រូវប្រគល់ឱ្យខេត្តថវិកាណាត្រូវប្រគល់ឱ្យឃុំថវិកាណាត្រូវប្រគល់ឱ្យស្រុកថវិកាណាដែលរដ្ឋបាលកណ្តាលទទួលយក។ ចំណូល ចំណាយ ក៏អញ្ចឹង។ កាលពីជំនាន់អតីតៈរដ្ឋកម្ពុជា យើងធ្លាប់បានធ្វើគឺខេត្តរកបើកប្រាក់ខែខ្លួនឯងហើយត្រូវបង់ឱ្យថ្នាក់កណ្តាល។ បានសេចក្តីថារបៀបចាត់ចែងមួយចំនួនកាលអតីតៈរដ្ឋកម្ពុជាមានប្រសិទ្ធភាព។ កាលហ្នុង ដាច់ស្ពានត្រឹម២០ម៉ែត្រ ខេត្តអត់មានស្រែករកមជ្ឈិមទេ។ រឺដាច់ស្ពានពីយប់ ព្រលឹមឡើងបងប្អូននៅថ្នាក់ ខេត្ត គេចាត់ចែងធ្វើបាត់ហើយ។ ឥឡូវនេះ សូម្បីតែជ្រុះក្តារតែ៥បន្ទះ ក៏ស្រែករកមកលើដែរ។ ព្រោះខាង លើយកអំណាចមកអស់រលីងហើយ។ ដូច្នេះ មានចំណុចមិនដូចគ្នាទេ ប៉ុន្តែមានចំណុចខ្លះប្រហាក់ប្រហែល គ្នាដែរ។ សុំបញ្ជាក់ជូនអំពីបញ្ហាហ្នឹង ហើយកុំព្រួយបារម្ភថាសិទ្ធិរដ្ឋមន្ត្រីចង់បាត់អស់ទៅហើយ។ យើងនៅជារដ្ឋមន្ត្រីទទួលខុសត្រូវផ្នែកហ្នឹងដដែលទេ។ ប៉ុន្តែយើងឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិនោះជាអ្នកធ្វើការងារ។ ភាពជោគជ័យគឺសម្រាប់ប្រទេសទាំងមូល ហើយមិនត្រូវបារម្ភរឿងអស់តួនាទីអស់ស្អីនោះឱ្យសោះ។ យើងត្រូវមានគំនិតមួយថាយើងធ្វើដើម្បីប្រទេសជាតិមិនមែនធ្វើដើម្បីខ្លួនយើងនោះទេហើយយើងធ្វើសម្រាប់រយៈពេលវែងមិនមែនសម្រាប់រយៈពេលដែលអស់លោកអង្គុយជារដ្ឋមន្ត្រីនោះទេ។

នេះគ្រាន់តែជាការអធិប្បាយបន្ថែមទៅលើបញ្ហានេះបន្តិច។ កន្លងទៅថាវិមជ្ឈការ តែទីបំផុតនៅតែសួរមករដ្ឋមន្ត្រីដដែល។ ឥឡូវនេះអត់សួររដ្ឋមន្ត្រីទេ ព្រោះចៅហ្វាយខេត្តចុះហត្ថលេខា ហើយក្រុមប្រឹក្សា ធ្វើច្បាប់ រៀបចំអ្វី១នៅថ្នាក់ខេត្តឯណោះ។ នៅថ្នាក់ខេត្ត មានគណៈអភិបាលជាអ្នកធ្វើការងារ។ ប៉ុន្តែមានផ្នែកដែលត្រូវផ្ទេរ និងមានផ្នែកដែលមិនត្រូវផ្ទេរ។

បច្ចុប្បន្ននេះ **គ.ជ.អ.ប** មានលទ្ធភាពអាចសហការជាមួយរដ្ឋបាលគ្រប់កម្រិត រួមមានក្រសួង ស្ថាប័ន និងក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិទាំងមូល ដើម្បីសម្រេចនូវទិសដៅជារួមនៃការកសាង លើកកម្ពស់ និងចីរភាពនៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ។ រចនាសម្ព័ន្ធ និងប្រព័ន្ធ **គ.ជ.អ.ប** ត្រូវបានរៀបចំឡើងយ៉ាងល្អប្រសើរសម្រាប់បំពេញការងារនេះ ហើយធនធាននានានឹងត្រូវបានប្រគល់ឱ្យដើម្បី

ធានានូវប្រសិទ្ធិភាពនៃការបន្តការងារនៃរដ្ឋបាល។ ក្រសួងជាគន្លឹះមួយចំនួនដូចជា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃ ត្រូវដើរនៅជួរមុខក្នុងការរៀបចំនូវគោលនយោបាយជាយុទ្ធសាស្ត្រនានា។ ក្រសួងទាំងនេះត្រូវសហការគ្នាយ៉ាងជិតស្និទ្ធ ដើម្បីធានាបាននូវប្រសិទ្ធភាពនៃការអនុវត្ត។ ក្រសួង ស្ថាប័នដទៃទៀត ក៏ត្រូវធ្វើការសិក្សាដោយយកចិត្តទុកដាក់អំពីតួនាទី ការទទួលខុសត្រូវ និងមុខងារនានាក្នុងក្របខ័ណ្ឌដែលកំពុងមាននាពេលបច្ចុប្បន្ននេះ និងក្នុងក្របខ័ណ្ឌដែលតួនាទី ការទទួលខុសត្រូវ និងមុខងារទាំងនេះនឹងត្រូវផ្លាស់ប្តូរក្រោមកិច្ចដំណើរការកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ។ រាជរដ្ឋាភិបាលរំពឹងថា ក្រសួងនីមួយៗនឹងខិតខំផ្សារភ្ជាប់ខ្លួនជាមួយគោលនយោបាយវិមជ្ឈការនិងវិសហមជ្ឈការ និងច្បាប់រៀបចំអង្គការ ហើយនឹងប្រកាន់យកនូវការទទួលខុសត្រូវខ្ពស់ក្នុងការអនុវត្តគោលនយោបាយ និងច្បាប់នេះ។ ជារួម កិច្ចដំណើរការនេះនឹងត្រូវបានគាំទ្រដោយកម្មវិធីជាតិ ហើយការគាំទ្រផ្នែកបច្ចេកទេសនិងហិរញ្ញវត្ថុ ក៏នឹងត្រូវបានផ្តល់ជូនក្រសួងពាក់ព័ន្ធសំខាន់ៗ ដើម្បីអនុវត្តការងារទាំងនោះផងដែរ។

នៅពេលដែលក្រុមប្រឹក្សាថ្មីត្រូវបានបង្កើតឡើង ក្រុមប្រឹក្សាទាំងនេះនឹងត្រូវផ្សារភ្ជាប់ខ្លួនជាមួយគោលនយោបាយវិមជ្ឈការនិងវិសហមជ្ឈការ និងច្បាប់រៀបចំអង្គការ។ ក្រុមប្រឹក្សាទាំងនេះត្រូវពិចារណាអំពីតួនាទី និងការទទួលខុសត្រូវថ្មីរបស់ខ្លួន ព្រមទាំងរួមចំណែកដល់ការពិភាក្សានិងការអនុវត្តគោលនយោបាយវិមជ្ឈការនិងវិសហមជ្ឈការ និងកម្មវិធីជាតិ។ របៀបរបបការងារថ្មីនេះតម្រូវឱ្យក្រុមប្រឹក្សាទាំងនោះធ្វើការពិគ្រោះយោបល់ និងចូលរួមជាមួយដៃគូនានានៅមូលដ្ឋាន ដែលរួមមានវិស័យឯកជន និងសង្គមស៊ីវិល ដើម្បីអភិវឌ្ឍន៍ចក្ខុវិស័យ និងផែនការអភិវឌ្ឍរបស់ខ្លួន។ ទន្ទឹមនេះ ក្រុមប្រឹក្សានានានៅថ្នាក់ក្រោមជាតិ ត្រូវរៀបចំក្នុងការទទួលយកនូវការទទួលខុសត្រូវនិងមុខងារថ្មីៗ ដែលនឹងត្រូវផ្ទេរទៅឱ្យរួមជាមួយធនធានសមត្ថភាពសមស្របមួយ។ បែបផែនដែលត្រូវបំពេញនេះ នឹងជះឥទ្ធិពលយ៉ាងធំធេងដល់ការសម្រេចបាននូវការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ជាមួយការផ្តល់នូវសេវាប្រកបដោយគុណភាព និងការឆ្លើយតបនឹងតម្រូវការនានារបស់មូលដ្ឋាន។ ជាមួយគ្នានេះដែរ តាមរយៈកម្មវិធីជាតិ យើងនឹងផ្តល់នូវការណែនាំ និងការគាំទ្រនានាដល់ក្រុមប្រឹក្សាទាំងនេះ សម្រាប់ការធ្វើផែនការ និងការអនុវត្តកិច្ចការនេះ។

ដើម្បីសម្រេចបាននូវគោលបំណង និងទិសដៅខាងលើនេះ នាពេលខាងមុខ ស្ថាប័នអភិបាលកិច្ចមួយនឹងត្រូវដាក់ជំនួសស្ថាប័នអភិបាលកិច្ចនៅរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។ នៅខាងមុខនេះ នៅថ្នាក់រដ្ឋបាលទាំងនេះ នឹងបង្កើតឱ្យមានក្រុមប្រឹក្សានិងគណៈអភិបាល ដែលមានលក្ខណៈខុសពីប្រព័ន្ធបច្ចុប្បន្នដែលមានតែអភិបាល។ ច្បាប់រៀបចំអង្គការសម្រាប់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ បានបញ្ជាក់រួចហើយអំពីទំនាក់ទំនង ការទទួលខុសត្រូវ និងគណនេយ្យភាពនៃអង្គការទាំងពីរនេះ។ ប៉ុន្តែទោះបីយ៉ាងនេះ ក៏នៅតែមានការបកស្រាយផ្សេងៗគ្នាមួយចំនួនដែលក្នុងឱកាសនេះខ្ញុំសូមគូសបញ្ជាក់អំពីទំនាក់ទំនងរវាងអង្គការទាំងពីរនេះឡើងវិញ។ ក្នុងក្របខ័ណ្ឌនៃលទ្ធិប្រជា ធិបតេយ្យ និងច្បាប់រៀបចំអង្គការ ក្រុមប្រឹក្សាមានអំណាចនីតិបញ្ញត្តិ និងអំណាចនីតិប្រតិបត្តិ។ក្រុមប្រឹក្សាតំណាងឱ្យផលប្រយោជន៍នៅក្នុងមូលដ្ឋានហើយត្រូវមានគណនេយ្យភាព

ជាបឋមចំពោះមូលដ្ឋាននិងចំពោះរាជរដ្ឋាភិបាល។ ចំពោះគណៈអភិបាលគ្រាន់តែជាមន្ត្រីដែលអនុវត្តការងារតាមការសម្រេចរបស់ក្រុមប្រឹក្សា និងត្រូវមានគណនេយ្យភាពចំពោះក្រុមប្រឹក្សារបស់ខ្លួន។ ផ្អែកតាមច្បាប់ ក្រុមប្រឹក្សាអាចស្នើផ្លាស់ប្តូរគណៈអភិបាលបានប្រសិនបើមន្ត្រីក្នុងគណៈអភិបាលណាមួយអនុវត្តមិនត្រឹមត្រូវតាមតួនាទីភារកិច្ចរបស់ខ្លួន។ នេះជារបៀបចាត់ចែងការងារថ្មីនៅមូលដ្ឋានដើម្បីលើកកម្ពស់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ដែលទាមទារឱ្យមានការផ្លាស់ប្តូរទម្លាប់និងឥរិយាបថ ក្នុង រយៈពេលខាងមុខនេះ។

ចំណុចនេះសូមបញ្ជាក់ថា ឥឡូវនេះយើងមានតែគណៈគ្រប់គ្រងខេត្ត។ រដ្ឋបាលថ្នាក់ក្រោមជាតិ សព្វថ្ងៃនេះមានអភិបាលខេត្ត និងបណ្តាអភិបាលរង ។ ខាងមុខនេះនៅពេលបោះឆ្នោតរួចហើយ យើងនឹងមានការគ្រប់គ្រងរដ្ឋបាលនេះមានផ្នែកពីរ :- មួយគឺក្រុមប្រឹក្សាដែលកើតឡើងតាមការបោះឆ្នោត និងមួយទៀតគឺគណៈអភិបាលដែលត្រូវតែងតាំង។ គណៈអភិបាលដែលត្រូវបានតែងតាំងនេះ គឺរួមមានអភិបាលខេត្ត និង អភិបាលរង ដែលមាន ៧ ៦ ៥ តាមខេត្តធំ ខេត្តតូច ។

ឥឡូវយើងនិយាយពីទំនាក់ទំនងរបស់វា។ ដំបូង ត្រូវនិយាយអំពីទំនាក់ទំនងរវាងក្រុមប្រឹក្សាជាមួយអ្នកណា? ក្រុមប្រឹក្សាជាបឋមត្រូវមានគណនេយ្យភាពជាមួយមូលដ្ឋានរបស់ខ្លួនរួចហើយត្រូវមានគណនេយ្យភាពជាមួយរាជរដ្ឋាភិបាល ។មុននេះអ្នកច្បាប់បរទេសមួយចំនួនមកសរសេរឱ្យក្រុមប្រឹក្សានេះមានគណនេយ្យភាពជាមួយសភាជាតិ។ នោះគឺជាអ្នកច្បាប់ ស្ទើរភ្លើង រៀនមិនទាន់ចប់ ហើយមកសរសេរច្បាប់នៅស្រុកខ្មែរ ដែលឱ្យក្រុមប្រឹក្សាមានគណនេយ្យភាពជាមួយនឹងរដ្ឋសភានោះ។ តាមការពិត ក្រុមប្រឹក្សានេះត្រូវមានគណនេយ្យភាពជាមួយរាជរដ្ឋាភិបាល។ ដូច្នោះ ដូចជាផែនការអភិវឌ្ឍន៍ខេត្ត ឬគម្រោងថវិកាខេត្ត មិនមែនត្រូវយកទៅធ្វើគណនេយ្យភាព សុំការអនុម័តពីសភាដាច់ដោយឡែកទេ។ គឺត្រូវយកមកឱ្យរាជរដ្ឋាភិបាលដើម្បីបញ្ចូលទៅក្នុងច្បាប់ថវិកាជាតិតែមួយ។ អញ្ចឹង ប្រធានក្រុមប្រឹក្សានិងអភិបាលខេត្ត នាំគ្នាធ្វើផែនការតែ កុំចេះតែធ្វើផែនការលើកឡើងមកពេញបន្ទុក។ ពីដើមខ្ញុំឧស្សាហ៍ថាឱ្យឯកឧត្តម គាត់ ថន រដ្ឋមន្ត្រីហិរញ្ញវត្ថុ។ គាត់ថាទៅសុំលុយពី កោះកុង និងសុំលុយពីកំពង់សោម។ ខ្ញុំថាមិនមែនសុំទេ កុំប្រើពាក្យសុំ គឺទៅយក។ ព្រោះកាលហ្នុងច្រកពន្ធគយគឺមកតាមហ្នុងច្រើន ហើយនិងនៅខេត្តកណ្តាល ខេត្តកំពង់ចាម ស្វាយរៀង។ ប៉ុន្មានខេត្តហ្នឹងជាខេត្តដែលសល់លុយ។ ខ្ញុំថាទៅយកព្រោះគេគួសខ្ទង់ឱ្យអ្នកឯងចាយប៉ុណ្ណឹងទំហំចំណូលប៉ុណ្ណេះហើយត្រូវបង់ប៉ុណ្ណេះហើយអ្នកឯងមិនព្រមបង់។

ដូច្នេះមិនមែនទៅសុំទេគឺទៅយក។ អញ្ចឹងទំនាក់ទំនងនេះមានចែងនៅក្នុងច្បាប់ហើយ។ ដូច្នោះ តើទំនាក់ទំនងនោះមានលក្ខណៈយ៉ាងម៉េចរវាងក្រុមប្រឹក្សានិងគណៈអភិបាល?។

គណៈអភិបាលគឺជាអ្នកអនុវត្ត ហើយគណៈអភិបាលនេះ មានការអី ត្រូវទំនាក់ ទំនងជាមួយក្រុមប្រឹក្សា។ ឯក្រុមប្រឹក្សានេះ ត្រូវទំនាក់ទំនងមករាជរដ្ឋាភិបាល មិនមែនទៅសភាទេ។ សូម កុំភន្តច្រឡំកន្លែងនេះ។ ព្រោះមានអ្នកច្បាប់មកពីប្រទេសណាមួយ ខ្ញុំមិនបញ្ចេញឈ្មោះទេ មកដល់សរសេរ ច្បាប់ឱ្យក្រុមប្រឹក្សានេះមានគណនេយ្យភាពជាមួយសភា។ អញ្ចឹងរាជរដ្ឋាភិបាលធ្វើអី?។ ប៉ុន្តែគ្រាន់តែមាន

ផ្នែកពីរ មួយគឺបោះឆ្នោតដែលអង្គបោះឆ្នោតនោះគឺសមាជិកក្រុមប្រឹក្សាឃុំសង្កាត់បច្ចុប្បន្ននេះ និងបោះឆ្នោតថ្ងៃទី ១៧ ខែឧសភា ខាងមុខនេះ ជាលើកដំបូងនៅក្នុងប្រទេស របស់យើងបង្កើតបាននូវក្រុមប្រឹក្សានេះ ។ ឯមួយផ្នែកទៀតគណៈអភិបាលដែលជាអ្នកអនុវត្តគឺត្រូវតែងតាំងដោយព្រះរាជក្រឹត្យនិងអនុក្រឹត្យដូចអភិបាល និងអភិបាលរងខេត្តសព្វថ្ងៃនេះ។ ក៏ប៉ុន្តែត្រូវកាត់បន្ថយចំនួនហើយ ព្រោះឥឡូវនេះវាកកស្ទះពេញទឹកពេញដីហើយត្រង់ហ្នឹង។ ប៉ុន្តែកាត់ទុកកន្លែងខ្លះទុក៥ទេ កន្លែងខ្លះទុក៦ កន្លែងខ្លះទុក៧។ អញ្ចឹង ត្រូវគិតគូរគ្នាមើលទៅ អ្នកណាទៅ ឈរឈ្មោះ។ ឈរឈ្មោះទៅដូចជាម្យ៉ាងដែរ ខ្ញុំគ្រាន់តែជូនយោបល់ទេណា។ បើខ្ញុំវិញ ធ្វើអនុរដ្ឋលេខាធិការ រាល់ថ្ងៃនេះខ្ញុំសុខចិត្តទៅនៅខេត្តវិញវាល្អជាង។ អនុរដ្ឋលេខាធិការមួយចំនួនមិនស្រួលទេនៅក្រសួងនោះទៅនៅខេត្តវិញបម្រើប្រជាជនបានច្រើនជាង។ ទៅឈរឈ្មោះជាសមាជិកក្រុមប្រឹក្សាខេត្តទៅ។ កន្លែងខ្លះគេពិបាករក សុំឈរជាប្រធានទៅ។ អញ្ចឹងទេគឺថ្លឹងថ្លែងមើលទៅ។ ប៉ុន្តែខ្ញុំសូមបញ្ជាក់ តាមច្បាប់ ក្រុមប្រឹក្សាអាចស្នើផ្លាស់ប្តូរ មន្ត្រីក្នុងគណៈអភិបាលបាន។ ប៉ុន្តែមិនមែនថា អស់លោកស្នើមក ខ្ញុំត្រូវតែព្រមតាមនោះទេ សុំបញ្ជាក់ជូន។ ច្បាប់អនុញ្ញាត ក៏ប៉ុន្តែត្រូវឆ្លងកាត់មកមហាផ្ទៃ។ មហាផ្ទៃត្រូវសួរយោបល់នាយករដ្ឋមន្ត្រី ថាដូរឬមិនដូរ?។ ឯមហាផ្ទៃចុះអង្កេត។ អញ្ចឹង អស់លោកមួយចំនួននោះស្នើដូរអត់ចប់ទេ ចាំមើលស្នើដូរអត់ចប់ទេ ព្រោះគេថាមុខដដែល១។ ចុះបើពួកប្រឆាំងមុខដដែល១ដែរ ឱ្យគេកាន់អំណាចមុខផ្លាស់ទៅណា?។ ពួកប្រឆាំងនិយាយអញ្ចឹង ថាពួកកាន់អំណាចមុខដដែល១។ អញ្ចឹង យើងថាត្រឡប់ទៅវិញ ចុះអ្នកប្រឆាំងមុខដដែល១ដែរ ម៉េចក៏មិនថា ផង។ ការពិតទៅមុខដដែល១ប្រឆាំងគេមុខដដែល១មិនដែលឈ្នះគួរតែដើរចេញទៅ។ ព្រោះមិនដែលអ្នកណាឡើងរើយកខ្សែក្រវាត់៤ដងនៅ តែដួលសន្លប់ ហើយនៅតែបន្តធ្វើខ្លាំងទេ។ គេអ្នកកាន់អំណាច គេត្រូវឡើងការពារខ្សែក្រវាត់។ និយាយឱ្យ ច្បាស់មើល៍ លោកឯងនៅតែនិយាយថាមុខដដែល១ ចុះមុខលោកឯងយកទៅណា? ពួកប្រឆាំងមុខដដែលដែរអញ្ចឹងអ្នកកាន់អំណាចត្រូវមុខដដែលដែរ។ ប៉ុន្តែបើនិយាយឱ្យពិតឥឡូវយើងមើលអាមេរិក ចន ឃែរី កាលគាត់ឈរមិនឈ្នះ ចច ប៊ូស។ លើកក្រោយនេះគាត់អត់ឈរទេពីខាងប្រជាធិបតេយ្យ។ គេរុញ អូបាម៉ា ឡើងទៅឈរ ឈ្នះបាត់ទៅហើយ។ ឃើញទេ? ស្រុកឯងនេះខ្លួនឯងមុខប្រឆាំងដដែល១ មករអ៊ូរដាក់គេអ្នក ជាប់ឆ្នោតមុខដដែល១។ អាហ្នឹងនិយាយមិនគិតខ្លួនឯងសោះ។ ឥឡូវ បញ្ចេញកញ្ចប់ថវិកា ៥០០លាន។ គេ ធ្វើរួចមុនទៅហើយ។ មិនទាន់ទាំងបានបញ្ជូនលិខិតមកដល់ដៃខ្ញុំផង ស្រាប់តែផ្សាយតាមកាសែតឯណោះ។ អញ្ចឹង មិនបាច់ឆ្លើយ។ ខ្ញុំបានទទួលទូរស័ព្ទថា នៅមានលិខិតមកខ្ញុំមួយឱ្យត្រៀមកញ្ចប់ថវិកា ៥០០លាន។ សូមបញ្ជាក់ទៅវិធានការជាកញ្ចប់របស់រាជរដ្ឋាភិបាលមានច្រើនជាង ៥០០លាន ប៉ុន្មានដងឯណោះ ស្តារ ហេដ្ឋារចនាសម្ព័ន្ធ។ គ្រាន់តែហេដ្ឋារចនាសម្ព័ន្ធប៉ុន្មានទៅកំពុងតែធ្វើទេ កំពុងដំណើរការធ្វើ គាំទ្រនេះ គាំទ្រ នោះ។ ឥឡូវថ្ងៃនេះឮថាគេអញ្ជើញ ឯកឧត្តម គាត ឈន់ ឱ្យឡើងទៅប្រាប់នៅសភា។

ច្បាស់ហើយ ក្រុមប្រឹក្សាតំណាងឱ្យផលប្រយោជន៍មូលដ្ឋាន មានគណនេយ្យភាពជាបឋមជាមួយរាជរដ្ឋាភិបាល។ ចំពោះគណៈអភិបាល តាមផ្លូវច្បាប់ ក្រុមប្រឹក្សាអាចស្នើផ្លាស់ប្តូរអភិបាលបាន ប្រសិនបើមន្ត្រីក្នុងគណៈអភិបាលណាមួយ អនុវត្តមិនត្រឹមត្រូវតាមតួនាទីរបស់ខ្លួន។ អញ្ចឹង នឹងមានសំណើជាប់រហូតអត់ចប់ទេ ខេត្តណាក៏ដោយ ចំពោះការដាក់ញត្តិដកអភិបាលខេត្ត អភិបាលរងខេត្ត។ ប៉ុន្តែ បានសេចក្តីថា ទប់គ្នា។ គេហៅថា តុល្យភាព នោះ។ ប៉ុន្តែគេក៏ស្នើឱ្យយើង ៩០កៅអី តុល្យភាពជាមួយ៣កៅអីដែរ យីចេះនិយាយទៅរួច។ នេះជាមនុស្សដែលហៅថាមុខក្រាស់។ អញ្ចឹងបានខ្ញុំថា ធ្វើបក្សប្រឆាំងទាល់តែមុខក្រាស់។ មុខមិនក្រាស់ ធ្វើមិនបាន។ មុខក្រាស់រហូតដល់កាប់ ១០០ប៉ុំងតោក៏វាមិនមុតដែរ។ ដូច្នោះត្រៀមទៅអភិបាលខេត្តមួយចំនួនត្រៀមឱ្យហើយទៅ។ គេមានគ្នាប៉ុន្មាននាក់ហ្នុង គេស៊ីញ៉េសុំដក អភិបាលខេត្តនេះ សុំដកអភិបាលរងនោះ។ ហើយមហាផ្ទៃចុះអង្កេត បើវាមានរឿងពិតប្រាកដគឺត្រូវតែរើត្រូវដក តែបើវាអត់មានរឿងផង ចេះតែដកក៏វាមិនកើត។

ពាក់ព័ន្ធនឹងបញ្ហាខាងលើនេះ មានសំណួរចោទសួរថា តើក្រុមប្រឹក្សាថ្មីទាំងនោះនឹងត្រូវបំពេញការងារនៅកន្លែងណា? ហើយគណៈអភិបាលត្រូវបំពេញការងារនៅកន្លែងណា? តាមការគូសបញ្ជាក់របស់ខ្ញុំខាងលើនេះ ពិតណាស់ថា សាលារាជធានីភ្នំពេញ សាលាខេត្ត ក្រុង ស្រុក ខណ្ឌ គឺជាកន្លែងបំពេញការងាររបស់ក្រុមប្រឹក្សានិងគណៈអភិបាល។ យើងអាចពង្រីកកន្លែងធ្វើការទាំងនោះជាជំហានៗ តាមលទ្ធភាពនៃធនធានរបស់យើង។

អញ្ចឹងបញ្ជាក់ នៅក្នុងសាលាខេត្តជាមួយគ្នាហ្នឹង មានទៅនៅឯណា។ ពង្រីកកន្លែងធ្វើការទៅ។ ថ្ងៃមុនខ្ញុំថាឱ្យឧត្តរមានជ័យដីនៅធំណាស់។ ប៉ុន្តែរាល់ថ្ងៃនេះគឺថា កន្លែងខ្លះគាត់ធ្វើធំៗណាស់ ហើយប៉ុន្មានបន្ទប់បន្ថែមទៀតសម្រាប់អស់លោកនេះដែលត្រូវបោះឆ្នោត។ ឥឡូវខេត្តធំមានប៉ុន្មាន? ខេត្តដែលធំជាងគេបួនមានសមាជិកប៉ុន្មាន? អញ្ចឹងត្រូវត្រៀមធ្វើការនៅកន្លែងហ្នឹង។ ក៏ប៉ុន្តែយើងក៏ត្រូវត្រៀមប្រាក់ខែដែរ។ ឯអស់លោកហ្នឹងយើងមិនទាន់កំណត់ថាប្រាក់ខែប៉ុន្មានទេ ប្រហែលជាមិនតិចទេមើលទៅ។ ប៉ុន្តែយ៉ាងណាក៏ដោយ នេះការងារដែលចាំបាច់ត្រូវធ្វើ។ នៅពេលនោះ ពេលមានការអី អស់លោកបើកអង្គប្រជុំដូចជាសម័យប្រជុំកូនសភាតូចមួយនៅនឹងខេត្តហ្នឹងទៅ។ ជជែកគ្នាទៅកុំឱ្យឈឺក្បាលដល់ថ្នាក់ជាតិនោះច្រើនពេក។ អស់លោកនាំគ្នាធ្វើកិច្ចការ ប៉ុន្តែមិនមែនឱ្យទៅហ្នុងដើម្បីទៅទាស់គ្នាទេ ឱ្យនាំគ្នាអភិវឌ្ឍន៍។ ប៉ុន្តែយើងក៏បានដឹងទុកជាមុនហើយថា លទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស ហ្នឹង បិទមាត់គេមិនឱ្យប្រឆាំងក៏មិនកើតដែរ។ត្រូវក៏ប្រឆាំងខុសក៏ប្រឆាំងបើមិនប្រឆាំងទើបចំឡែក។ អាហ្នឹងនិយាយអញ្ចឹងតែម្តងទៅ។ ត្រៀមខ្លួនឱ្យហើយទៅអស់លោកអភិបាលខេត្ត អភិបាលរាជធានី។ បើគេមិនប្រឆាំងទើបវាចំឡែក។ ធ្វើត្រូវក៏ប្រឆាំង ធ្វើ មិនត្រូវក៏ប្រឆាំង។ ឥឡូវមហាសម្ពន្ធ័ភាពស្អីឯណា រួចហើយថាឯងខ្លាចចាំខ្លាចតើអាពៅ សល់៥ឆ្នាំទៀត។ ឆ្នាំ ២០១៣ អស់លោកឯងហ្នឹង មុខឡើងកញ្ចាស់ហើយ។ ឆ្នាំ២០១៣យូរដែរ មិនមែនស្រួលឯណា។ ឥឡូវនេះទើប២០០៩ទេតើ។ ពេលនោះយើងទទួល

បានផ្លែផ្កាមួយចំនួនពីការអនុវត្តកិច្ចការនេះ ។ការធ្វើនេះគឺដើម្បីប្រទេសជាតិទេ ។ បើថ្ងៃក្រោយអស់លោកឈ្នះ យកទៅក្រុមប្រឹក្សាហ្នុង ។ អស់លោក ឈ្នះ យកទាំងក្រុមប្រឹក្សា យកទាំងស៊ីហ្នុងទៅ ។ ព្រោះលោកឯងបោះឆ្នោតឃុំ សង្កាត់ឈ្នះ មានន័យថា ក្រុមប្រឹក្សានេះនឹងត្រូវបោះឆ្នោតនៅឆ្នាំ ២០១៥ ។ ២០១៥ ក្រុមប្រឹក្សានេះលោកឯងឈ្នះ ព្រោះលោកឯង ឈ្នះឃុំ សង្កាត់ភាគច្រើនទៅហើយ ។ ឯ ២០១៣ លោកឯងឈ្នះសភាទៀត ។ លោកឯងធ្វើទាំងរដ្ឋាភិបាល ទាំងថ្នាក់ជាតិ ទាំងថ្នាក់ឃុំ ទាំងថ្នាក់ស្រុកផង ទាំងថ្នាក់ខេត្តផង លោកឯងស៊ីទៅ យកទៅ ធ្វើទៅ ។ ហើយកុំ មកស្រែកមុខដដែល ៗហ្នឹង ។ ខ្ញុំក៏ប្រាប់ចង្អុលត្រឡប់ទៅវិញ មុខអ្នកឯងប្រឆាំងតែដដែល ៗតាំងពីដើមរហូត ដល់ចប់ ។ ប្រឆាំងតាំងពីជំនាន់រួមជាមួយប៉ុលពត រិះគន់រដ្ឋាភិបាល រិះគន់រដ្ឋាភិបាលអតីតៈរដ្ឋកម្ពុជា អ្នកឯងប្រឆាំងមុខដដែល ៗ ។ ហើយខ្ញុំសុំបញ្ជាក់ចំណុចមួយមិនដោះដូរទេ ។ អញ្ចឹងមុខខ្ញុំដដែល ៗ ទាល់តែមុខលោកដដែល ៗដើរចេញដែរ ដើម្បីឱ្យថ្មីទាំងអស់គ្នា ។ ហ្អេ អត់ដោះដូរអាហ្នឹងទេ ។ មិនដែលអាណាគេធ្វើអញ្ចឹងទេ ។ ប៉ុន្តែឈ្នះត្រូវយ៉ាងហោចណាស់ ត្រូវបង្ហាញមុខក្នុងពេលការពារខ្សែក្រវាត់ បើអ្នកឯងរើខ្ញុំដួល ខ្ញុំប្រគល់ខ្សែក្រវាត់ឱ្យ ។ ទោះបីខ្ញុំមិនប្រគល់ ក៏អាប៊ីតគេយកទៅពាក់ឱ្យអ្នកឈ្នះដែរ ។ និយាយមិនចេះខ្មាស់គេ ។ ហើយប៉ុន្មានថ្ងៃនេះ បង្កើនសម្លេងខ្លាំងណាស់ ក្រុមគេហ្នឹង ។ ប៉ុន្តែខ្ញុំគ្រាន់តែលើកឡើងមួយចំនួនទេដើម្បីអស់លោកបានត្រៀមគំនិតទុកឱ្យហើយ ។ពីមុននោះគឺថាមានតែអភិបាលនិងអភិបាលរងទេដែលធ្វើការ ។ តែឥឡូវនេះ យើងនៅឈរនៅហ្នឹងមានក្រុមប្រឹក្សាមួយដែលចេញពីការបោះឆ្នោត ។ អញ្ចឹងក្រុមប្រឹក្សានេះមានសិទ្ធិនឹង ស្នើដកហូតអភិបាលឬសមាជិកមន្ត្រីក្នុងគណៈអភិបាល ។ ប៉ុន្តែការដកហូតនេះមិនមែនស្នើមកគឺត្រូវតែដកទេ ស្នើមិនត្រូវគឺមិនដកទេ ។ បងឆាយ សារ៉េតដូចជាត្រៀមធ្វើប្រធានក្រុមប្រឹក្សា? ត្រូវហើយយើងហួសអាយុ ហើយ ហួសជីឡេហើយ ។ ណាំ ទុំ យ៉ាងម៉េចដែរ? ត្រៀមទៅ កូនសម្បុកអីនៅហ្នុងហើយ ចាំបាច់ធ្វើស្នើអី មក ។ ប៉ុន្តែដាក់ទៅមុខតែមានហើយ លោកប្រធានក្រុមប្រឹក្សាស្នើដូរលោកនេះចេញ ដូរលោកនោះចេញត្រៀមទុកឱ្យហើយទៅ ។ សមាជិកសភាដូចទៅពីនេះមួយត្រឡប់បកទៅកំពតវិញ បងឃឹម សាម៉ន? គាត់សុខចិត្តទៅពីសមាជិកសភា ទៅឈរជាប្រធានក្រុមប្រឹក្សាខេត្ត ។

នេះខ្ញុំគ្រាន់តែលើកក្នុងរង្វង់គណបក្សប្រជាជនមួយចំនួនដែលកំពុងកាន់ការជាសមាជិកសភា ហើយនឹងត្រូវទៅធ្វើជាប្រធានក្រុមប្រឹក្សាខេត្តអី តែប៉ុណ្ណឹងទេ ។ គ្រាន់តែថា ឱ្យត្រៀមស្មារតីឱ្យហើយ រឿងវាយ៉ាងដូច្នេះឯង ។ អញ្ចឹងសុំឱ្យលោកខេត្តត្រៀមពីឥឡូវទៅឱ្យហើយ ។ លោកខេត្តនានាត្រៀមលក្ខណៈសម្បត្តិថាខាងណា កន្លែងណាទុកគណៈអភិបាល ដែលមានរួមមាន អភិបាលខេត្តនិងអភិបាលរង ។ បើថាខេត្តធំ ខេត្ត ៧ នាក់ ត្រូវមានអភិបាលរង៦នាក់ ។ ប៉ុន្តែខ្ញុំសុំប្រាប់ថា ថ្នាក់ស្រុកក៏ដោយ ថ្នាក់ខេត្តក៏ដោយ ត្រូវទុកនារី១ឱ្យបានម្នាក់ ហើយផ្នែកខាងឈរឈ្មោះហ្នឹងក៏ត្រូវឱ្យនារីឱ្យឈរឱ្យច្រើនដែរ ។ ប៉ុន្តែផ្នែក ខាងនីតិប្រតិបត្តិគឺគណៈអភិបាលរបស់ខេត្ត គណៈអភិបាលរបស់ស្រុកនិងខណ្ឌ ត្រូវទុកនារីម្នាក់ឱ្យបានធ្វើអភិបាល

រងក្នុងគណៈអភិបាល ខាងផ្នែកនីតិប្រតិបត្តិ។ ព្រោះគោលការណ៍កន្លងទៅយើងបានដាក់ចេញមកឱ្យមានអភិបាលរងស្រុកមួយអភិបាលរងខេត្តមួយជាស្ត្រី។ ដល់ទៅពេលមានការផ្លាស់ប្តូរបែរជាអស់ស្រីរលីងអស់តាំងពីគណៈអភិបាល អត់មានទាំងក្នុងក្រុមប្រឹក្សាទៀត មិនបានទេ។ ក៏ប៉ុន្តែយើងមិនដាក់កូតាទេ តែយើងនឹងខិតខំ។ កូតាមាន នៅក្នុងគណៈអភិបាលហើយ កូតាឱ្យមួយ។ និយាយអញ្ចឹងគឺ កូតាមួយៗអញ្ចឹងតែម្តង។ សូម្បីក្នុងក្រសួង មហាផ្ទៃ ឋានៈរដ្ឋលេខាធិការមានស្ត្រីមួយដែរ។ ខាងថ្នាក់ខេត្ត និងថ្នាក់ស្រុក ផ្នែកនីតិប្រតិបត្តិ គឺមានមួយ ទាំងអស់។ អញ្ចឹង បុរសៗមិនគួរគប្បីច្រណែននឹងមុខតំណែងរបស់នារីនោះទេ។ ជួយលើកទឹកចិត្តឱ្យធ្វើការ ឱ្យល្អ។ បើថ្ងៃក្រោយទៅមានលទ្ធភាព អាចឡើងធ្វើអភិបាលខេត្ត ឬក៏អីអញ្ចឹងទៅ។ ជិតដល់៨មីនាហើយ ទាល់តែនារីខ្លួនឯង ប្រឹងខ្លួនឯងដែរ។ ប៉ុន្តែមិនដឹងយ៉ាងម៉េចនារីៗហ្នឹង? គ្រាន់តែបើថា បេក្ខជនបុរស និង បេក្ខជននារីឈរក្នុងអង្គប្រជុំបោះឆ្នោត ដែលមាននារី៦០% បុរសមានតែ៤០%ទេ។ បេក្ខជនដែលជាប់ឆ្នោត គឺមិនមែននារីទេ តែគឺបុរសទៅវិញ។ គាត់មិនព្រមបោះឆ្នោតឱ្យគ្នាគាត់ផង ហើយគាត់មកស្នើឱ្យយើងគាំទ្រ ទៅគាត់។ ឥឡូវសាកល្បងមើល៍ ឱ្យមាននារី៦០នាក់ បុរស៤០នាក់ ក្នុង១០០នាក់អង្គបោះឆ្នោត។ ដាក់បេក្ខជន ពីរនាក់ មួយបុរស មួយស្ត្រី ហើយបោះឆ្នោតមើល៍។ បោះឆ្នោតអាចជាប់បុរស អត់ជាប់ស្ត្រី?រឿងវាអញ្ចឹង។ តែនេះ គ្រាន់តែជាការរំលឹកទេដើម្បីកុំឱ្យភ្លេចទុកស្ត្រីមួយរូប។ ផ្នែកខាងគណបក្សប្រជាជនបានចេញសារាចរណែនាំទៅគ្រប់មូលដ្ឋាន ហើយដើម្បីរៀបចំនៅក្នុងគណៈអភិបាលហ្នឹង។ អញ្ចឹង ផ្នែកនារីៗមិនត្រូវកង្វល់ថា បន្តិចទៀតគេមានការផ្លាស់ប្តូរទៅអស់នារីហើយ គឺអត់ទេ នារីៗគឺទុក ប៉ុន្តែទុកតែមួយបានហើយ។ បើថាមានពីរ មួយឱ្យមកឈរខាងក្រុមប្រឹក្សា ឱ្យមានខាងក្រុមប្រឹក្សាខ្លះ ហើយមាននៅខាងគណៈអភិបាលខ្លះទៅ។

ទទី្មនេះ ការបែងចែកឡើងវិញនូវមុខងារនានាពីថ្នាក់ជាតិទៅថ្នាក់ក្រោមជាតិ ជាពិសេសពាក់ព័ន្ធនឹងការផ្តល់សេវា គឺពិតជាកិច្ចដំណើរការមួយមានលក្ខណៈស្មុគស្មាញ។ យើងមិនមែនគ្រាន់តែគិតថា ត្រូវផ្ទេរមុខងារចំបងៗមួយចំនួនដូចជា សេវាសុខភាពបឋម ឬការអប់រំក្នុងកម្រិតបឋមនោះទេ។ ប៉ុន្តែ យើងត្រូវតែមានការពិចារណាយ៉ាងច្បាស់លាស់ថា តើមុខងារណាមួយដែលសមស្របបំផុតជាមួយនឹងថ្នាក់រដ្ឋបាលកម្រិតណាមួយ ព្រមជាមួយនោះ តើត្រូវរៀបចំហិរញ្ញវត្ថុ មនុស្ស និងធនធានអ្វីខ្លះទៀតដែលពាក់ព័ន្ធនឹងមុខងារនោះ និងការរៀបចំផែនការយ៉ាងដូចម្តេច ដើម្បីផ្ទេរមុខងារ និងធនធានទាំងនេះឱ្យសមស្របទៅនឹងសមត្ថភាពសម្រាប់ថ្នាក់រដ្ឋបាលដែលត្រូវទទួលមុខងារនោះ។ ប្រសិនបើសមត្ថភាពនៃថ្នាក់រដ្ឋបាលនោះ នៅពុំទាន់មានគ្រប់គ្រាន់ យើងត្រូវផ្ទេរនូវធនធាន ឬក៏កសាងនូវសមត្ថភាពជូនថ្នាក់រដ្ឋបាលនោះ ដែលនេះជាការទទួលខុសត្រូវរបស់ក្រសួងដែលបានផ្ទេរមុខងារ ដើម្បីធានាថាកិច្ចការនេះត្រូវបានសម្រេចទៅតាមកាលបរិច្ឆេទដ៏សមស្របមួយ។

ដំណើរការខាងលើនេះ ច្បាស់លាស់ណាស់ថានឹងមានការប៉ះពាល់មកលើតួនាទីនិងការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័នថ្នាក់ជាតិដែលនឹងមានការផ្លាស់ប្តូរផងដែរ។ ក្នុងកិច្ចដំណើរការនេះ ក្រសួងនានានឹងរក្សាទុកនូវការទទួលខុសត្រូវជារួមក្នុងវិស័យរបស់ខ្លួន រួមមានការតាក់តែងគោលនយោបាយ ការត្រួតពិនិត្យពីលើការរៀបចំលិខិតបទដ្ឋាន ការផ្តល់យោបល់និងការគាំទ្រ ការអង្កេតឃ្លាំមើល និងការវាយតម្លៃចំពោះការបំពេញកិច្ចការរបស់ក្រុមប្រឹក្សា។ ថ្នាក់ក្រោមជាតិនឹងត្រូវមានគណនេយ្យភាពចំពោះរាជរដ្ឋាភិបាល និងមានគណនេយ្យភាពផ្នែកហិរញ្ញវត្ថុតាមរយៈសវនកម្ម និងគោលការណ៍សុវត្ថិភាពហិរញ្ញវត្ថុដទៃទៀត។ ក្នុងន័យនេះ គ.ជ.អ.ប ត្រូវមានតួនាទីត្រួតពិនិត្យពីលើ ដើម្បីធានាថា ក្រុមប្រឹក្សានៅទូទាំងប្រទេសបំពេញកិច្ចការសម ស្របទៅតាមច្បាប់ និងក្របខ័ណ្ឌគតិយុត្តិនានា ហើយនឹងមិនផ្ទុយពីរដ្ឋធម្មនុញ្ញ។

ពាក់ព័ន្ធនឹងការងារយោធា សន្តិសុខ បច្ចុប្បន្ន រដ្ឋបាលថ្នាក់ក្រោមជាតិនានា រួមទាំងឃុំ សង្កាត់ផងបានទទួលនូវតួនាទីមួយចំនួនក្នុងការថែរក្សាការពារសន្តិសុខ សណ្តាប់ធ្នាប់ក្នុងមូលដ្ឋានរបស់ខ្លួន តាមរយៈយន្តការគណៈបញ្ជាការឯកភាព សំដៅចូលរួមជាមួយរាជរដ្ឋាភិបាលក្នុងការពង្រឹងសន្តិភាព ស្ថេរភាពនយោបាយ។ តួនាទី និងការទទួលខុសត្រូវនេះត្រូវអនុវត្តបន្តទៀតដោយក្រុមប្រឹក្សា និងគណៈអភិបាល ក្រោមគោលការណ៍វិសហមជ្ឈការ មិនមែនវិមជ្ឈការនោះឡើយ។

ក្នុងកិច្ចដំណើរការកំណែទម្រង់បន្តទៀត យើងត្រូវតែមានការប្រុងប្រយ័ត្ននៅក្នុងកិច្ចដំណើរការនៃការបង្កើតក្រុមប្រឹក្សា និងការបែងចែកនូវមុខងារឱ្យទៅឱ្យក្រុមប្រឹក្សាទាំងនោះលើមូលដ្ឋាននៃការធានាថានឹងពុំធ្វើឱ្យមានការរាំងស្ទះដល់កិច្ចការរបស់ក្រុមប្រឹក្សាឃុំសង្កាត់ ឬធ្វើការសម្រេចចិត្តណាមួយដែលប៉ះពាល់ដល់សិទ្ធិអំណាចរបស់ក្រុមប្រឹក្សាទាំងនោះឡើយ។ សារៈសំខាន់នៃរដ្ឋបាលថ្នាក់នេះ ដោយសារសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវបានបោះឆ្នោតជ្រើសរើសដោយផ្ទាល់ពីប្រជាពលរដ្ឋ ទទួលបាននូវទំនុកទុកចិត្តពីប្រជាពលរដ្ឋនៅក្នុងមូលដ្ឋានរបស់ខ្លួន ហើយគឺជាអ្នកដែលឈរនៅជួរមុខនៃប្រព័ន្ធអភិបាលកិច្ចមូលដ្ឋាន ដែលមានការចូលរួម និងប្រជាធិបតេយ្យ។

ខ្ញុំសូមបញ្ជាក់លើចំណុចពីរទាក់ទងនឹងការងារការពារ ការងារយោធា និងសន្តិសុខ។ ប្រទេសណាក៏ ដោយឱ្យសិទ្ធិអំណាចប៉ុនណាក៏ដោយ តែមានបញ្ហាពីរដែលគេត្រូវតែមានការគិតគូរ។ ទី១- ផ្នែកកិច្ចការ បរទេសគេមិនដែលឱ្យខេត្តបង្កើតស្ថានទូតនៅបរទេសទេ សូមបញ្ជាក់ជូនឱ្យហើយ។ តិចថា អូ អញឯករាជ្យ ហើយជិតជារដ្ឋស្វយ័តហើយ... មិនមែនអញ្ចឹងទេ កិច្ចការបរទេសអត់ទេ។ អាចអនុញ្ញាតជូនបណ្តាអង្គទូតបរទេសទស្សនកិច្ចនៅក្នុងខេត្តរបស់ខ្លួន។ ប៉ុន្តែខ្លួនមិនអាចបញ្ជូនតំណាងបេសកកម្មរបស់ខេត្ត ទៅនៅប្រចាំនៅប្រទេសណាមួយបានទេ។ អត់មានលើកទង់ជ័យដោយឡែកបានទេ... អាហ្នឹងនិយាយគ្នាឱ្យច្បាស់។ ក្របខណ្ឌនៃការផ្ទេររឿងកិច្ចការបរទេសគឺអត់ទេ។ អត់មានថា ខេត្តខ្ញុំត្រូវមាននយោបាយផ្សេង... ឥឡូវខ្ញុំទាក់ទងជាមួយតៃវ៉ាន់ហើយ អត់មានទាក់ទងជាមួយចិនដីគោកទេ... ឬខ្ញុំទទួលស្គាល់ទាំងពីរ អត់បានទេ

អាហ្នឹង គឺខុសច្បាប់ហើយ។ ឯបញ្ហាទី២គឺបញ្ហាយោធា សន្តិសុខ។ កន្លងទៅ យើងធ្វើបានល្អហើយជាទូទៅ។ ការសម្របសម្រួលប្រព័ន្ធដែលមានដូចជាឥឡូវនេះនៅថ្នាក់ឃុំគឺយើងមានប៉ុស្តិ៍រដ្ឋបាលឃុំដែលធ្វើការសហការជាមួយនឹងក្រុមប្រឹក្សាឃុំសង្កាត់។ យើងមានខណ្ឌ ស្រុក ដែលមានយោធា គេហៅថាផ្នែកសឹករង ដែលមាន ទំនាក់ទំនងយ៉ាងល្អជាមួយនឹងគណៈបញ្ជាការឯកភាព ដែលមានអភិបាលស្រុក ខណ្ឌ។ ហើយយើងមានសឹក រងខេត្ត ដែលឥឡូវហ្នឹងពាក់ឧត្តមសេនីយ៍ហើយព្រោះស្មើកងពលដែរទ័ពច្រើនដែរ មេប៉េអឹម មេប៉ូលិស។ អញ្ចឹងប្រព័ន្ធនេះគឺថាល្អហើយ បន្តប្រព័ន្ធហ្នឹងតទៅទៀត។ មិនមែនបានសេចក្តីថាកាត់ប្រព័ន្ធនេះចោលហើយនោះទេ។ គឺនៅក្នុងនេះបានបញ្ជាក់ថា វាជាវិសហមជ្ឈការ មិនមែនវិមជ្ឈការទេណា។ តួនាទីនៅទីនេះមិនមែនប្រគល់កងទ័ពឱ្យអស់លោកដាច់ឬប្រគល់ប៉ូលីសឱ្យអស់លោកដាច់នោះទេ។ អាហ្នឹងគោលការណ៍ វិសហមជ្ឈការ មិនមែនវិមជ្ឈការទេ។ វិមជ្ឈការបានសេចក្តីថាផ្តល់ឱ្យទៅតែម្តង។ ពិតណាស់ហើយនៅតាមខេត្តនីមួយៗមានកងពលនៃកងទ័ពស្រួចដែលជាកងទ័ពថ្នាក់យោធភូមិភាគនិងថ្នាក់កងទ័ពជើងគោកកងពលនៃអង្គភាពជើងគោក និងកងពលនៃអគ្គបញ្ជាការឈរជើង។កន្លងទៅ យើងមានទម្លាប់រៀបចំឱ្យ មានកិច្ចសហការរវាងកងទ័ពដែលឈរក្នុងដែនដីនៃខេត្តទាំងនោះជាមួយនឹងអភិបាលខេត្ត។ ទំនាក់ទំនងនេះ ខ្ញុំគិតថា យើងត្រូវកែលំអឱ្យសហការគ្នាកាន់តែល្អ។ មិនមែនបានសេចក្តីថាផ្ទេរឱ្យអស់លោកកាន់កងពល ទាំងអស់នោះ ហើយផ្ទេរឱ្យអស់លោកប្រើប្រាស់ទាហាន ឬកម្លាំងប្រដាប់អាវុធនោះ តាមចិត្តចង់នោះទេ។ បញ្ជាក់ឡើងវិញ មិនមែនវិមជ្ឈការទេ គឺវិសហមជ្ឈការនៅកន្លែងនេះ។ អញ្ចឹង ផ្នែកកិច្ចការបរទេសនេះមួយ ផ្នែកយោធា សន្តិសុខនេះពីរ អត់ជូនបានទេ។ កងយោធា ខាងការងារបរទេស អត់មានឱ្យអស់លោកទៅដាក់ ទូតនៅក្រៅទេ។ មុននឹងធ្វើស្អីទំនាក់ទំនងទៅក្រៅត្រូវឆ្លងកាត់ក្រសួងការបរទេស។ ទៅក្រៅមានទំនាក់ទំនងជាមួយស្ថានទូតយើងនៅឯបរទេស។ មិនមែនជារដ្ឋឯករាជ្យដែលត្រូវមានទូតដាក់តាំងទូតនៅក្រៅហ្នឹងទេ។ កងទ័ពគឺយើងដែលអនុវត្តប្រព័ន្ធរយៈពេលកន្លងទៅហ្នឹងគឺត្រូវហើយ អត់មានអីខុសទេ។ គ្រាន់តែថាធ្វើម៉េចឱ្យវាបន្ត។ ដល់ពេលហ្នឹងស្រាប់ថា អញកាន់ទាហានហើយ ទាហាន ប៉ូលិស ប៉េអឹម អញយកទាំងអស់ គ្រប់គ្រងទាំងអស់ ជូនអត់បានទេអាហ្នឹង។ នេះជាឧបករណ៍របស់រាជរដ្ឋាភិបាល។ តែជូនឱ្យអស់លោកបញ្ជានៅពេលដែលមានប្រតិបត្តិការទាក់ទងរយៈពេលកន្លងទៅ។ រឿងឡើងសក្តិក៏អស់លោកអត់មានសិទ្ធិតម្លើងដែរ។ អស់លោកអាចមានសិទ្ធិតម្លើងត្រឹមប្រធានមន្ទីរ ប្រធានការិយាល័យចំណុះ។ នេះគេហៅថារដ្ឋបាលឯកភាព ហើយ យើងបែងចែកសមត្ថកិច្ចហើយ។ ពួកគាត់ គ្នាគាត់ហ្នឹង គាត់រើសនៅហ្នុងទៅ។ កុំឱ្យវាទាស់គ្នាទៀត ពិបាករដ្ឋមន្ត្រីចង់បានឈ្មោះ ក ចៅហ្វាយខេត្តចង់បានឈ្មោះ ខ ឥឡូវប្រគល់ឱ្យខេត្ត។ ប៉ុន្តែនៅការជជែកគ្នា អំពីបញ្ហាហ្នឹងថែមទៀត។ ខ្សែទទឹង ខ្សែបណ្តោយយ៉ាងម៉េច ធនធានយ៉ាងម៉េច បន្តជជែកគ្នាថែមទៀត។ ប៉ុន្តែសូមបញ្ជាក់ឱ្យហើយ កុំភ័ន្តច្រឡំ ថាអនុវត្តច្បាប់ហ្នឹង បានហើយ ប្រុយហើយអញ ចង់ទាក់ទងតែវ៉ាន់យូរ ហើយ។ អញ្ចឹងអញដាក់ជាមួយតែវ៉ាន់មួយគ្រាំងសិន យកលុយសិន

អត់បានទេអាហ្នឹងខុសក្បួន។ នយោបាយបែបការបរទេសអត់បានទេ។ នយោបាយការបរទេសរបស់ព្រះរាជាណាចក្រកម្ពុជាគឺចិនតែមួយទេ។ តៃវ៉ាន់ គ្រាន់តែជាខេត្តមួយរបស់ចិនតែប៉ុណ្ណោះ។ ទំនាក់ទំនងរកស៊ីបាន ប៉ុន្តែគឺទំនាក់ទំនងនយោបាយការទូត គឺអត់ បានទេ និយាយឱ្យច្បាស់។ មន្ត្រីអ្នកនយោបាយគឺអត់មានឱ្យទៅតៃវ៉ាន់ទេ ហើយមន្ត្រីអ្នកនយោបាយតៃវ៉ាន់ ក៏អត់ឱ្យចូលកម្ពុជាដែរ។ឃើញមុខសញ្ញាទាក់ទងជាមួយនឹងតំណាងរាស្ត្រ ជាទីប្រឹក្សាប្រធានាធិបតី ឬក៏ថ្នាក់ ស្អី១អត់ទេ សុំកាត់វីសាចេញមិនឱ្យចូលទេ។ អ្នករកស៊ីចូលមកចុះ កប៉ាល់ហោះពីតៃវ៉ាន់មកប៉ុន្មានជើងឯណោះក្នុងមួយថ្ងៃ។ មានក្រុមហ៊ុនពីរផងគឺ អេវ៉ាអ៊ែរ និងឆាយណាអ៊ែរ។ ពីរក្រុមហ៊ុនហ្នឹងហោះរកស៊ីឯកជន។ ប៉ុន្តែ មិនអាចទាញទង់ជ័យតៃវ៉ាន់ចូលដីខ្មែរបានទេ។ គេដាក់សញ្ញាអីផ្សេង ឡូហ្គោអីផ្សេងទៅ។ ប៉ុន្តែទាញទង់ជ័យ តៃវ៉ាន់ចូលស្រុកខ្មែរគឺអត់ សុំបញ្ជាក់ជូន។ តិចលោលេងច្រឡំ អូ... បោះឆ្នោតហើយយើងបានដៃហើយអញ ចង់ទាក់ទងយូរហើយ អត់បានទេអាហ្នឹង។

មួយផ្នែកទៀត ខ្ញុំក៏ចង់បញ្ជាក់ជូនដែរថា ក្រុមប្រឹក្សាក្រោយការបោះឆ្នោតនេះកុំធ្វើឱ្យរាំងស្ទះនូវសិទ្ធិ អំណាចការធ្វើការសម្រេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់។ ត្រូវមើលឱ្យច្បាស់ណាស់។ ក្រុមប្រឹក្សាឃុំ សង្កាត់ប្រជាជនបោះឆ្នោតជាសាកលជូនដោយផ្ទាល់ជូន។ ហើយអស់លោកទាំងឡាយ ដែលនឹងកើតទៅជាក្រុមប្រឹក្សាស្រុក និងក្រុមប្រឹក្សាខេត្ត គឺអ្នកទាំងនោះជាអ្នកបោះឆ្នោតជូនអស់លោក។ អញ្ចឹងមិនមែនបង្កើតបានអស់លោកហើយអស់លោកទៅបំពានសិទ្ធិរបស់ក្រុមប្រឹក្សាដែលប្រជាជនបោះឱ្យផ្ទាល់ទេ។ អញ្ចឹងចំណុចនេះជាចំណុចដែលយើងត្រូវថ្លឹងថ្លែង។ រឿងមួយគឺពាក់ព័ន្ធជាមួយនឹងបញ្ហាឃុំ ដែលប្រជាជនបោះឆ្នោតដោយផ្ទាល់ ទំនាក់ទំនងជាមួយនឹងអាជ្ញាធរដែលមានការបោះឆ្នោតអសាកល គឺក្រុមប្រឹក្សាស្រុក ខណ្ឌ ក្រុង និងគណៈអភិបាលដែលមានការតែងតាំងពីរាជរដ្ឋាភិបាល។ អញ្ចឹង ចំណុចនេះជាចំណុចដែលយើងត្រូវតែមានភាពហ្មត់ចត់ ស្វែងរករូបមន្តសម្របសម្រួលឱ្យបានល្អ។ បើមិនអញ្ចឹង ទៅជាស្រុកទៅបំពានឃុំហើយឃុំក៏មិនខ្វីស្តាប់អ្នកណា អាងតែប្រជាជនបោះឆ្នោតឱ្យ។ អាហ្នឹងវាទៅជារឿងមួយទៀតហើយ។ អញ្ចឹង ចំណុចនេះបានជាខ្ញុំនិយាយថា ដាក់ក្នុងគោលដៅរយៈពេលវែង។ ធ្វើផង រៀនផង កែលំអផង។ ចំណុចណាដែលវាល្អចំណុចណាដែលវាមិនល្អសមស្រប យើងមានការដកនូវពិសោធន៍ដើម្បីតម្រង់ទិស។ យើងធ្វើផែនការដល់ទៅ១០ឆ្នាំឯណោះ ហើយយើងក៏ថ្មីថ្មោង។ ពេលថ្មីថ្មោង កុំអាលថាបរាជ័យ។ ហើយខ្ញុំសុំផ្តាំ ដួលត្រង់ណាត្រូវក្រោកត្រង់ហ្នឹង។ អាហ្នឹងជាវិធីជោគជ័យ ដួលកន្លែងណាត្រូវក្រោកកន្លែងហ្នឹង។ បើដួលកន្លែងហ្នឹង ធ្វើអាហ្នឹងមិនជោគជ័យទេ រកវិធីក្រោកចេញពីកន្លែងហ្នឹងឱ្យបាន។ អាហ្នឹងជាបទពិសោធន៍។ ៣០ឆ្នាំដែលគណបក្សប្រជាជនដឹកនាំប្រទេសចេញពីបាតដៃទទេ។ ដួលកន្លែងណា ក្រោកកន្លែងហ្នឹង។ ហើយក៏មិនត្រូវអំពាវនាវហៅអ្នកណាឱ្យមកជួយលើកដែរ។ ឧទាហរណ៍ កំណែទម្រង់ដីធ្លីនៅក្នុងទសវត្សរ៍៨០ ប្រឹងធ្វើទៅធ្វើមិនជោគជ័យ ធ្វើវាឃើត ឡើងទៅសភា។ បើមិនកែរដ្ឋធម្មនុញ្ញចំណុចហ្នឹងទេ ធ្វើវាមិនចេញ។ ហើយពេលនោះសម្តេចប្រធាន ជា ស៊ីម គាត់ប្រធានសភា សម្តេចហេង សំរិន គាត់ប្រធានរដ្ឋ ខ្ញុំជានាយករដ្ឋមន្ត្រី។

ខ្ញុំថាបើទុកតែអញ្ចឹងគឺអត់បាន។ អញ្ចឹងទេ គាត់អនុញ្ញាតភ្លាម១ឱ្យធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ ដោយគ្មានការគ្រោងទុក បើកច្រកឱ្យមានកំណែទម្រង់រហូតដល់ថ្ងៃនេះ។ ដួលត្រង់ណាក្រោកត្រង់ហ្នឹង។ នេះជាបទពិសោធន៍ ថ្មីថ្មោងរបស់យើង។ ប៉ុន្តែខ្ញុំគិតថា យើងក៏មានភាពចាស់ទុំដែរ។ ៣០ឆ្នាំម្នាក់១ ខ្លះក៏២០ឆ្នាំម្នាក់១ មានបទ ពិសោធន៍ច្រើនណាស់ហើយដែរ។

សំខាន់ជាងនេះទៅទៀត យើងត្រូវរៀបចំនូវប្រព័ន្ធដ៏សមស្របមួយ ដើម្បីធានាថា ក្រុមប្រឹក្សាថ្មី ដែលបានជ្រើសរើសដោយការបោះឆ្នោតនៅខែឧសភាខាងមុខនេះ នឹងត្រូវមានគណនេយ្យភាពយ៉ាងពេញលេញចំពោះអ្នកបោះឆ្នោតឱ្យខ្លួន ពោលគឺសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់។ ការបំពេញគណនេយ្យភាពចុះក្រោមនេះមានសារៈសំខាន់បំផុតសម្រាប់ជំនឿជឿជាក់នៃប្រព័ន្ធបោះឆ្នោតថ្នាក់ក្រោមជាតិទាំងមូល រួមទាំងប្រសិទ្ធិភាពនៃការផ្តល់សេវា និងការអភិវឌ្ឍថ្នាក់ក្រោមជាតិ។

***ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី!***

យើងនឹងត្រូវខិតខំប្រឹងប្រែងចំណាយពេលវេលា និងធនធានជាច្រើន សម្រាប់ការអនុវត្តកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ ហើយយើងសង្ឃឹមថា កំណែទម្រង់នេះនឹងផ្តល់នូវផលចំណែកនានាក្នុងក្របខ័ណ្ឌនៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ក្នុងក្របខ័ណ្ឌនៃការពង្រឹង និងពង្រីកការផ្តល់សេវាកាន់តែប្រសើរឡើង និងប្រកបដោយគុណភាព និងជាពិសេសកាត់បន្ថយភាពក្រីក្រ។

យើងក៏សង្ឃឹមថា កំណែទម្រង់នេះនឹងផ្តល់នូវផលចំណែកក្នុងក្របខ័ណ្ឌនៃអភិបាលកិច្ចផងដែរ។ ក្របខ័ណ្ឌយុទ្ធសាស្ត្រស្តីពីកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ បានគូសបញ្ជាក់ពីគោលនយោបាយសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ តាមរយៈការរៀបចំឡើងវិញ និងការកែទម្រង់នូវរដ្ឋបាលថ្នាក់ក្រោមជាតិទាំងមូល។ ចក្ខុវិស័យនៅក្នុងក្របខ័ណ្ឌយុទ្ធសាស្ត្របានចែងថា: "អភិវឌ្ឍប្រព័ន្ធគ្រប់គ្រងថ្នាក់ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ដោយផ្អែកលើគោលការណ៍នានានៃការចូលរួមតាមបែបប្រជាធិបតេយ្យ។ ប្រព័ន្ធនេះនឹងធ្វើប្រតិបត្តិការប្រកបដោយតម្លាភាព និងគណនេយ្យភាព ក្នុងគោលបំណងលើកកម្ពស់ការអភិវឌ្ឍ និងការផ្តល់សេវាកម្មសាធារណៈនៅមូលដ្ឋាន ឱ្យឆ្លើយតបនឹងតម្រូវការរបស់ប្រជាជន និងរួមចំណែកដល់ការកាត់បន្ថយភាពក្រីក្រនៅក្នុងមូលដ្ឋានរបស់ខ្លួន"។ ដូច្នេះកំណែទម្រង់នេះគឺជាឱកាសមួយនៃការកសាងនូវប្រព័ន្ធរដ្ឋបាលមូលដ្ឋានមួយដែលឆ្លុះបញ្ចាំងពីគោលការណ៍សំខាន់១នៃអភិបាលកិច្ចល្អក្នុងនោះរួមមានគណនេយ្យភាពការផ្សាភ្ជាប់គ្នាទៅនឹងវិធាននៃច្បាប់ តម្លាភាព ការចូលរួមសមធម៌និងភាពឆ្លើយតប។ ទន្ទឹមនេះកំណែទម្រង់នេះចាំបាច់ត្រូវជំរុញការអនុវត្តជាក់ស្តែងនូវទិដ្ឋភាពពីរផ្សេងទៀតនៃអភិបាលកិច្ចល្អ ដែលពេលខ្លះគេអាចមើលរំលងពោលគឺ "ប្រសិទ្ធិភាព និងភាពស័ក្តសិទ្ធ" ដែលយើងនឹងខិតខំបញ្ជ្រាបទិដ្ឋភាពទាំងនេះទៅក្នុងក្រុមប្រឹក្សាទាំងនោះ។

ជាការពិត គោលនយោបាយវិមជ្ឈការនិងវិសហមជ្ឈការ ហើយនឹងច្បាប់រៀបចំអង្គការក៏បានផ្តល់ឱកាសសម្រាប់ពង្រឹងនូវសមភាពយេនឌ័រ និងការចូលរួមរបស់ស្ត្រីនៅក្នុងតួនាទីធ្វើការសម្រេចចិត្តនៅរដ្ឋបាលថ្នាក់ក្រោមជាតិផងដែរ ។ កំណែទម្រង់នេះក៏ផ្តល់ឱកាសក្នុងការលើកកម្ពស់សម្លេងរបស់យុវជនក្នុងការធ្វើការសម្រេចចិត្តដែលជាការត្រៀមរៀបចំឱ្យយុវជនក្លាយជាអនាគតនៃអ្នកដឹកនាំនៅគ្រប់កម្រិត។

***ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី!***

ខ្ញុំសូមគូសបញ្ជាក់ជាថ្មីឡើងវិញថា គ្រប់ក្រសួង ស្ថាប័ន និងថ្នាក់រដ្ឋបាលនានាចាំបាច់ត្រូវចូលរួមចំណែកនៅក្នុងការតាក់តែងរៀបចំ និងអនុវត្តនូវកម្មវិធីនេះ។ ពាក់ព័ន្ធនឹងបញ្ហានេះខ្ញុំសូមអំពាវនាវដល់ដៃគូអភិវឌ្ឍទាំងអស់ សូមជួយគាំទ្រយើងខ្ញុំទាំងផ្នែកហិរញ្ញវត្ថុ និងទាំងផ្នែកបច្ចេកទេស ដើម្បីផ្តល់លទ្ធភាពឱ្យយើងអាចអនុវត្តនូវកំណែទម្រង់នេះប្រកបដោយជោគជ័យ តាមរយៈការធានាថា រាល់គម្រោងនិងកម្មវិធីហិរញ្ញប្បទានសហប្រតិបត្តិការនាពេលបច្ចុប្បន្ននេះ ត្រូវបានតម្រឹមយ៉ាងជិតស្និទ្ធជាមួយនឹងកម្មវិធីជាតិ។

ខ្ញុំបានដឹងថា ការរៀបចំតាក់តែងច្បាប់រៀបចំអង្គការ និងការអនុវត្តច្បាប់នេះ ពិសេសការត្រៀមរៀបចំនានាដើម្បីធានាថា ក្រុមប្រឹក្សាដែលកើតចេញពីការបោះឆ្នោតនាខែឧសភាខាងមុខនេះ នឹងចាប់ផ្តើមដំណើរការបានភ្លាមនោះ បាននិងកំពុងធ្លាក់មកលើអម្រែកដ៏ធ្ងន់ធ្ងររបស់សមាជិក គ.ជ.អ.ប និងលេខាធិការដ្ឋានរបស់ខ្លួន ព្រមទាំង ឯកឧត្តម លោកជំទាវ លោក លោកស្រី ទាំងអស់ដែលមានវត្តមាននៅទីនេះ។ ជាការពិត យើងកំពុងប្រឈមមុខនឹងភារៈកិច្ចដ៏ស្មុគស្មាញមួយ ដែលនឹងត្រូវចំណាយពេលធ្វើការលើកំណាត់ផ្លូវដ៏វែង ដែលមានកិច្ចការដ៏លម្អិតក្នុងក្របខ័ណ្ឌនៃពេលវេលាជាកំហិតនេះ។ បច្ចុប្បន្ន យើងកំពុងស្ថិតនៅលើដើមផ្លូវនៃកិច្ចដំណើរការវិមជ្ឈការនិងវិសហមជ្ឈការ ។ ទោះបីជាមានការរវល់មមាញឹកក៏ពិតមែន ប៉ុន្តែវាជាមោទនភាពជាប្រវត្តិសាស្ត្រ ដែលយើងទាំងអស់គ្នាបានចូលរួមនៅក្នុងកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅកម្ពុជា។

ជាទីបញ្ចប់ ខ្ញុំសូមសម្តែងនូវការវាយតម្លៃខ្ពស់ចំពោះការចូលរួមដ៏ថ្លៃថ្លារបស់ ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី នៅក្នុងកិច្ចដំណើរការកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។ ខ្ញុំសូមសម្តែងនូវអំណរគុណជាពិសេស ចំពោះការជួយឧបត្ថម្ភគាំទ្រដ៏មានថ្លៃថ្លារបស់ដៃគូអភិវឌ្ឍនានា និងសូមថ្លែងអំណរគុណចំពោះ គ.ជ.អ.ប ដែលបានខិតខំប្រឹងប្រែងរៀបចំកិច្ចប្រជុំដ៏មានសារៈសំខាន់នេះ។ ខ្ញុំសូមប្រសិទ្ធិពរជូនចំពោះ ឯកឧត្តម លោកជំទាវ អស់លោក លោកស្រីទាំងអស់ សូមប្រកបដោយពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។ ”